B-549

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី 11 ខែ 06 ឆ្នាំ 2003

ក

# មាតិកា

## I.ខុទ្ទកាល័យព្រះមហាក្សត្រ

### ១.ព្រះរាជក្រឹត្យ


១៦-១០-២០០១ -ព្រះរាជក្រឹត្យ នស/រកត/១០០១/៣៦៨ ស្តីពីការបំពាក់មេដាយ **មាសការពារជាតិ** ជូនកងពលតូចលេខ ៧០ នៃអគ្គបញ្ជាការកងយោធពលខេមរភូមិន្ទ ២៨១៤

១៦-១០-២០០១ -ព្រះរាជក្រឹត្យ នស/រកត/១០០១/៣៦៩ ស្តីពីការតែងតាំង ឯកឧត្តម **សែម សារឿន** ជាអគ្គនាយកនៃនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ក្រសួងបរិស្ថាន ២៨១៥

១៩-១០-២០០១ -ព្រះរាជក្រឹត្យ នស/រកត/១០០១/៣៧៣ ស្តីពីការប្រោសព្រះរាជទានចំពោះលោកជំទាវ **ញៀម សឿន ជា ស៊ុម** នូវគ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រិយានីព្រះស៊ីសុវត្ថិមុនីវង្សកុសមនារីរ័ត្ន** ថ្នាក់ **មហាសេរីវឌ្ឍន៍** ២៨១៦

២០-១០-២០០១ -ព្រះរាជក្រឹត្យ នស/រកត/១០០១/៣៨៧ ស្តីពីការបំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ជូន ឯកឧត្តម **ឆា ចំរើន** ២៨១៧

២០-១០-២០០១ -ព្រះរាជក្រឹត្យ នស/រកត/១០០១/៣៨៨ ស្តីពីការបំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** ជូន ឯកឧត្តម **កែវ ឡុងឌី** ២៨១៨

២០-១០-២០០១ -ព្រះរាជក្រឹត្យ នស/រកត/១០០១/៣៨៩ ស្តីពីការតែងតាំង ឯកឧត្តមឧត្តមសេនីយ៍ឯក **តេង សាវង្ស** អគ្គនាយករងនគរបាលជាតិជាអគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំង គ្រឿងញៀនបន្ថែមលើមុខងារបច្ចុប្បន្ន ២៨១៩

២២-១០-២០០១ -ព្រះរាជក្រឹត្យ នស/រកត/១០០១/៣៩០ ស្តីពីការបំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ថ្វាយព្រះមហាសុមេធាធិបតី **ទេព វង្ស** សម្តេចព្រះសង្ឃរាជគណៈមហានិកាយ ២៨២០

២២-១០-២០០១ -ព្រះរាជក្រឹត្យ នស/រកត/១០០១/៣៩១ ស្តីពីការបំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា**ថ្នាក់**សេនា**ប្រគេនព្រះវិន័យសំវរ **មួងរ៉ា** នាយកប្រតិបត្តិអភិបាល កិច្ចសង្ឃនៃព្រះរាជាណាចក្រកម្ពុជានិងជាព្រះរាជាគណៈថ្នាក់ ចត្វានៃគណៈមហានិកាយ ២៨២១

២២-១០-២០០១ -ព្រះរាជក្រឹត្យ នស/រកត/១០០១/៣៩២ ស្តីពីការតែងតាំង លោក **សុទ្ធ សីន** ជា **ឧកញ៉ា** ២៨២២

២២-១០-២០០១ -ព្រះរាជក្រឹត្យ នស/រកត/១០០១/៣៩៣ ស្តីពីការតែងតាំងឯកឧត្តម **ស្បោង សារ៉ាត** ជា **ឧកញ៉ា** ២៨២៣

២២-១០-២០០១ -ព្រះរាជក្រឹត្យ នស/រកត/១០០១/៣៩៤ ស្តីពីការបំពាក់គ្រឿងឥស្សរិយយស

**ព្រះរាជាណាចក្រកម្ពុជា** និង **មុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ជូនឯកឧត្តមប្រធាននិង ឯកឧត្តមជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ចំនួន ០៨រូប ព្រមទាំងឯកឧត្តមអគ្គលេខា ធិការ អគ្គលេខាធិការរងចំនួន ០២រូប ២៨២៤

២៧-១០-២០០១ -ព្រះរាជក្រឹត្យ នស/រកត/១០០១/៤០៥ ស្តីពីការផ្លាស់តំណែង អ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ ផាន់ជាវ៉ាទច្ស** បច្ចុប្បន្នឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាពនៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសប្រ៊ុយណេទៅកាន់តំណែងជាឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាពនៃព្រះរាជាណាចក្រកម្ពុជាប្រចាំសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់វិញ ២៨២៦

២៧-១០-២០០១ -ព្រះរាជក្រឹត្យ នស/រកត/១០០១/៤០៦ ស្តីពីការតែងតាំង ឯកឧត្តម **អ៊ិត ជេតតូឡា** ជាឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាពនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំបទេស ប្រ៊ុយណេ ២៨២៧

## I- ក្រុមប្រឹក្សាធម្មនុញ្ញ

២២-១០-២០០១ - សេចក្តីសំរេចលេខ ០៤៥/០០៧/២០០១ កបធ.ច ២៨២៨

## II- រាជរដ្ឋាភិបាល

### ១~ អនុក្រឹត្យ

១៩-១០-២០០១ - អនុក្រឹត្យលេខ ១០៥ អនក្រ .បក ស្តីពីការបំបែកនាយកដ្ឋានអាស៊ី ប៉ាស៊ីហ្វិក ក្រៅពីអាស៊ាននៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិជានាយកដ្ឋានអាស៊ីទី១ និងនាយកដ្ឋានអាស៊ីទី២ ២៨៣០

២២-១០-២០០១ - អនុក្រឹត្យលេខ ១០៦ អនក្រ .បក ស្តីពីការធានារ៉ាប់រង ២៨៣៣

២២-១០-២០០១ - អនុក្រឹត្យលេខ ១០៧ អនក្រ .បក ស្តីពីប្រតិទិនឈប់សំរាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ២០០២ ២៨៦៧

២៤-១០-២០០១ - អនុក្រឹត្យលេខ ១០៨ អនក្រ .បក ស្តីពីការបង្កើតវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្ររបស់ក្រសួងអប់រំ យុវជននិងកីឡា ២៨៦៩

២៤-១០-២០០១ - អនុក្រឹត្យលេខ ១០៩ អនក្រ .បក ស្តីពីការតម្លើងឋានៈវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេសឱ្យមានឋានៈស្មើថ្នាក់នាយកដ្ឋាន ២៨៧១

២៤-១០-២០០១ -អនុក្រឹត្យលេខ ១១០ អនក្រ .បក ស្តីពីការតម្លើងឋានៈមជ្ឈមណ្ឌលបច្ចេកទេសនិងវិជ្ជាជីវៈ**ព្រះកុសមៈ**ទៅជាវិទ្យាស្ថានពហុបច្ចេកទេស**ព្រះកុសមៈ**របស់ក្រសួងអប់រំយុវជននិងកីឡា ២៨៧៣

១៧-១០-២០០១ - អនុក្រឹត្យលេខ ៤៣៨ អនក្រ .តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៨៧៥

៧-១០-២០០១ - អនុក្រឹត្យលេខ ៤៣៩ អនក្រ .តត ស្តីពីការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ

ជាកិច្ចបច្ឆាមរណៈ ២៨៧៦

១៨-១០-២០០១ - អនុក្រឹត្យលេខ ៤៤០ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៨៧៧

១៨-១០-២០០១ - អនុក្រឹត្យលេខ ៤៤១ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៨៧៨

១៩-១០-២០០១ - អនុក្រឹត្យលេខ ៤៤២ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៨៧៩

១៩-១០-២០០១ - អនុក្រឹត្យលេខ ៤៤៣ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៨៨០

១៩-១០-២០០១ - អនុក្រឹត្យលេខ ៤៤៤ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៨៨១

១៩-១០-២០០១ - អនុក្រឹត្យលេខ ៤៤៥ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៨៨២

១៩-១០-២០០១ - អនុក្រឹត្យលេខ ៤៤៦ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៨៨៣

១៩-១០-២០០១ - អនុក្រឹត្យលេខ ៤៤៧ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៨៨៤

១៩-១០-២០០១ - អនុក្រឹត្យលេខ ៤៤៨ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៨៨៥

១៩-១០-២០០១ - អនុក្រឹត្យលេខ ៤៤៩ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៨៨៦

១៩-១០-២០០១ - អនុក្រឹត្យលេខ ៤៥០ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៨៨៨

១៩-១០-២០០១ - អនុក្រឹត្យលេខ ៤៥១ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៨៨៩

១៩-១០-២០០១ - អនុក្រឹត្យលេខ ៤៥២ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៨៩០

១៩-១០-២០០១ - អនុក្រឹត្យលេខ ៤៥៣ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៨៩១

១៩-១០-២០០១ - អនុក្រឹត្យលេខ ៤៥៤ អនក្រ .តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៨៩២

១៩-១០-២០០១ - អនុក្រឹត្យលេខ ៤៥៥ អនក្រ .តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៨៩៤

២២-១០-២០០១ - អនុក្រឹត្យលេខ ៤៥៦ អនក្រ .តត ស្តីពីការជូនមេដាយសុវត្ថារា ២៨៩៥

២៥-១០-២០០១ - អនុក្រឹត្យលេខ ៤៥៧ អនក្រ .តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៨៩៦

២៥-១០-២០០១ - អនុក្រឹត្យលេខ ៤៥៨ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៨៩៧

២៥-១០-២០០១ - អនុក្រឹត្យលេខ ៤៥៩ អនក្រ .តត ស្តីពីការអនុវត្តន៍វិន័យមន្ត្រីនគរបាលជាតិ ២៨៩៩

២៦-១០-២០០១ - អនុក្រឹត្យលេខ ៤៦០ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩០០

២៦-១០-២០០១ - អនុក្រឹត្យលេខ ៤៦១ អនក្រ .តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៩០១

២៦-១០-២០០១ - អនុក្រឹត្យលេខ ៤៦២ អនក្រ .តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៩០២


## ២~ សេចក្តីសំរេច


២៦-១០-២០០១ -សេចក្តីសំរេចលេខ ៦៥ សសរ ស្តីពីការបង្កើតគណៈកម្មការដើម្បីចលនាអភិវឌ្ឍន៍ភូមិមួយ ផលិតផលមួយ និងត្រៀមរៀបចំសន្និសីទអាស៊ី- ក្បូស្ទ ស្តីពីចលនាភូមិមួយ ផលិតផលមួយ ២៩០៣

## III- ការិយាល័យក្រសួង

### ១- ឯកសារទីស្ដីការគណៈរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៨-១០-២០០១ - ប្រកាសលេខ២៩៤ MoC/M200ស្ដីពីលទ្ធផលនៃការដេញថ្លៃកូតាសំរាប់នាំចេញសំលៀកបំពាក់ទៅកាន់សហរដ្ឋអាមេរិកក្នុងឆ្នាំ ២០០១ ២៩០៥

### ២- ទីស្ដីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

១៨-១០-២០០១ - សេចក្ដីសំរេចលេខ ៤៣៨ សសរ.កសក ស្ដីពីការបង្កើតគណៈកម្មការកំណត់ដីភូមិ និងដីកសិកម្ម ដែលប្រជាពលរដ្ឋកំពុងធ្វើអាជីវកម្មក្នុងដែនព្រៃសម្បទាន ២៩០៩

### ៣- ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

១៦-១០-២០០១ -ប្រកាសលេខ ៦៨២ ឧរថកឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុនក្បាលកោះហ្គាមេន ខូអិលធីឌី ( KBAL KOAH GARMENT CO,LTD ) តំណាងដោយលោក LIN CHIN YI សញ្ជាតិចិនតៃវ៉ាន់ អាយុ ៤០ ឆ្នាំ បង្កើតរោងចក្រ "កាត់ដេរសំលៀកបំពាក់" ដែលមានឈ្មោះថា " ក្បាលកោះហ្គាមេន មានទីតាំង ស្ថិតនៅភូមិជ្រោយអំពិល ឃុំក្បាលកោះ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ២៩១១

១៦-១០-២០០១ -ប្រកាសលេខ ៦៨៣ ឧរថកឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន យៀលខាំបូឌា ម៉ូទ័រ ( វ៉ាយ ស៊ី អឹម )( YIEL CAMBODIA MOTOR Co,LTD ) ( YCM ) តំណាងដោយលោក **សាំង រចនា** សញ្ជាតិខ្មែរ អាយុ ៦៣ ឆ្នាំ បង្កើតរោងចក្រ "ផ្គុំតម្លើងម៉ូតូ" ដែលមានឈ្មោះថា " យៀលខាំបូឌា ម៉ូទ័រ ( វ៉ាយ ស៊ី អឹម) មានទីតាំងស្ថិតនៅដីឡូតិ៍ លេខ ៣១ផ្លូវលេខ ៥៩៨ និង ៣៣៩ សង្កាត់បឹងកក់ ២ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ២៩១៣

១៨-១០-២០០១ -ប្រកាសលេខ ៦៨៦ ឧរថកឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន កាងនីងខូអិលធីឌី ( KANG NINGCo,LTD ) តំណាងដោយលោក KAO KANG NING សញ្ជាតិចិន (តៃវ៉ាន់) អាយុ២៦ ឆ្នាំបង្កើតរោងចក្រផលិតប្រដាប់ព្យួរសំលៀកបំពាក់ដែលមានឈ្មោះថា " កាង នីង" មានទីតាំង ស្ថិតនៅផ្លូវលេខ ១៥ ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ២៩១៥

### ៤-ទីស្ដីការរដ្ឋមន្ត្រី ក្រសួង ផែនការ

១៧-១០-២០០១ - ប្រកាសលេខ ១៤១ ផ.ក ប្រក ស្ដីពីការបង្កើតក្រុមការងារ នៃអនុគណៈ កម្មការផែនការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ២៩១៧

# ព្រះរាជក្រឹត្យ

នស/រកត/១០០១/៣៦៨

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : បំពាក់មេដាយមាស ឥស្សរិយយសជាតិ ជូនកងពលតូចលេខ ៧០ នៃអគ្គបញ្ជាការកងយោធពលខេមរភូមិន្ទ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០១

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខ: ២៥៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] គាន់

# ព្រះរាជក្រឹត្យ

យើង

នស/រកត/១០០១/៣៦៩

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម សែម សារឿន ជាអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងបរិស្ថាន ។

**មាត្រា ២ :** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០១

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខៈ ៧៦០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង តាន់

# ព្រះរាជក្រឹត្យ

នស/រកត/១០០១/៣៧៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

ត្រាស់ព្រះរាជទាន

ចំពោះ

លោកជំទាវ ញ៉ែម សឿន ជា ស៊ីម

នូវ

គ្រឿងឥស្សរិយយស

សម្តេចព្រះមហាក្សត្រិយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុម នារីរ័ត្ន

ថ្នាក់ មហាសេរីវឌ្ឍន៍

ព្រះហស្ថលេខា

នរោត្តម សីហនុ

លេខ : ៨៦៤ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០១

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] តាន់

# ព្រះរាជក្រឹត្យ

នស/រកត/១០០១/៣៨៧

## យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : បំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ជូនឯកឧត្តម ទេះ ចាំរ៉ាត់ អតីតសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលមានស្នាដៃនិងគុណបំណាច់ដ៏ឧត្តុង្គឧត្តម ក្នុងការរៀបចំការបោះឆ្នោត អោយដំណើរការប្រកបដោយ តម្លាភាព និង យុត្តិធម៌ រួមចំណែកយ៉ាងសកម្មក្នុងការផ្សះផ្សា បង្រួបបង្រួមជាតិ ។

**មាត្រា ២** : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០១*

លេខៈ [illegible] ច.ល

ដើម្បីចម្លងចេញពីច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ [illegible] ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

សារ៉ុន តាន់

# ព្រះរាជក្រឹត្យ

នស/រកត/១០០១/៣៨៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

**មាត្រា ១** : បំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** ជូនឯកឧត្តម **កែវ ឡុងឌី** អតីតសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលមានស្នាដៃនិងគុណបំណាច់ដ៏ឧត្តុង្គឧត្តម ក្នុងការរៀបចំការបោះឆ្នោត អោយដំណើរការប្រកបដោយ តម្លាភាព និង យុត្តិធម៌ រួមចំណែកយ៉ាងសកម្មក្នុងការផ្សះផ្សា បង្រួបបង្រួមជាតិ ។

**មាត្រា ២** : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា

នរោត្តម សីហនុ

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០១*

លេខ: [illegible] ច.ល

ដើម្បីចម្លងចែកជូន

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាខ តាន់

នស/រកត/១០០១/៣៨៩

# ព្រះរាជក្រឹត្យ

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩៩៥ / ៦៥ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំង គ្រឿងញៀន
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៧៩៩ / ២៣ ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការតែងតាំងឯកឧត្តម ឧត្តមសេនីយ៍ឯក ឯម សំអាន ជាអគ្គលេខាធិការ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានទ្រង់យល់សំណើ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម ឧត្តមសេនីយ៍ឯក តេង សាវង្ស អគ្គនាយករងនគរបាលជាតិ ជាអគ្គលេខាធិការ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខ ៧៦១ ធ.ល

បានឃើញ [illegible]

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណារឌី តាន់

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០០១

# ព្រះរាជក្រឹត្យ

នស/រកត/១០០១/៣៩០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : បំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ថ្វាយព្រះមហាសុមេធាធិបតី ទេព វង្ស សម្តេចព្រះសង្ឃរាជគណៈមហានិកាយ ដែលព្រះអង្គមានស្នាព្រះហស្ត និង គុណបំណាច់ដ៏ឧត្តុង្គឧត្តម ក្នុងការបំពេញព្រះរាជបេសកកម្ម រយៈពេលជាង ២២ ឆ្នាំ ដើម្បីប្រព្រះមាតុ ជាតិ សាសនា ព្រះមហាក្សត្រ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខៈ ៥៦៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០១*

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible]

ព្រះរាជក្រឹត្យ

នស/រកត/១០០១/៣៩១

យើង

ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : បំពាក់គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ប្រគេនព្រះវិន័យសរ័រ ម៉ូច រ៉ា នាយកប្រតិបត្តិ អភិបាលកិច្ចសង្ឃនៃព្រះរាជាណាចក្រកម្ពុជា និងជា ព្រះរាជាគណៈថ្នាក់ឯកនៃគណៈមហានិកាយ ដែលព្រះអង្គជាមហាថេរៈដ៏ឆ្នើម និង មានគុណូបការៈដ៏ថ្លៃថ្លាក្នុងការពង្រីកវិស័យព្រះពុទ្ធសាសនា និង កិច្ចការបំរើសង្គមជាតិ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ៕

ព្រះហស្ថលេខា

នរោត្តម សីហនុ

លេខ: ៨៦៧ ច.ល

ដើម្បីចំលងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០១

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០១*

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង នីម តាន់

# ព្រះរាជក្រឹត្យ

នស/រកត/១០០១/៣៩២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

លោក សុទ្ធ សីន

ជា

ឧកញ៉ា

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខ: [illegible] ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាឌី តាន់

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០០១

# ព្រះរាជក្រឹត្យ

នស/រកត/១០០១/៣៩៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

**តែងតាំង**

ឯកឧត្តម **ស្បោង សារ៉ាត់**

**ជា**

**ឧកញ៉ា**

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

លេខៈ ២៦៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ១០ ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណឌី តាន់**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០១*

# ព្រះរាជក្រឹត្យ

នស/រកត/១០០១/៣៩៤

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

**ត្រាស់បង្គាប់**

**មាត្រា ១ :**

បំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** និង **មុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ជូនឯកឧត្តមប្រធាន និងឯកឧត្តមជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ចំនួន ០៨ រូប ព្រមទាំងឯកឧត្តមអគ្គលេខាធិការ អគ្គលេខាធិការរង ចំនួន ០២ រូប ដូចមានរាយនាមខាងក្រោម :

ក . គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ "**មហាសេរីវឌ្ឍន៍**"

១-ឯកឧត្តម **ប៊ិន ឈិន** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

២- ឯកឧត្តម **ចាន់ សុក** អតីតប្រធាន និងជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ

ខ . គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ "**មហាសេនា**"

១- ឯកឧត្តម **ថៅ ម៉េងឈាត** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ

២- ឯកឧត្តម **សាយ ប៊ុរី** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ

៣- ឯកឧត្តម **យ៉ន់ សែម** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ

៤- ឯកឧត្តម **ឆ្នាក់ សុខ** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ

៥- ឯកឧត្តម **តុប សំ** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ

គ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ " **មហាសេនា** "

១- ឯកឧត្តម **ស៊ិន** **ស៊ូប៉ើ្ត** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ

ឃ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ " **សេនា** "

១- ឯកឧត្តម **ពិត** **តាំងសាន** អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ

២- ឯកឧត្តម **ម៉េង** **គីមលី** អគ្គលេខាធិការរងក្រុមប្រឹក្សាធម្មនុញ្ញ

**មាត្រា ២.-**

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-**

ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ព្រះហស្ថលេខា**

**នរោត្តម សីហនុ**

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០០១

លេខ : ០០២ ចល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០០១

អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ

ពិត.តាំងសាន

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ________

# ព្រះរាជក្រឹត្យ

នស/រកត/១០០១/៤០៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្លាស់តំណែងអ្នកអង្គម្ចាស់ ស៊ីសុវត្ថិ ជាន់ដារ៉ាវង្ស បច្ចុប្បន្នឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសជប៉ុន ទៅកាន់តំណែងជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋ សហព័ន្ធអាល្លឺម៉ង់វិញ ។

**មាត្រា ២ :** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០១

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខ: ៥៧៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ១០ ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ ឆាន់

# ព្រះរាជក្រឹត្យ

នស/រកត/១០០១/៤០៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម អ៊ិត ដេតត្នូឡា ជាឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសប៉ូរ៉ុយរពោ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០១

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខ: ២៧៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២[illegible] ខែ តុលា ឆ្នាំ ២០០១

[illegible]រាជរដ្ឋាភិបាល

[illegible] តាន់

# ព្រះរាជាណាចក្រកម្ពុជា

ក្រុមប្រឹក្សាធម្មនុញ្ញ ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿង

លេខ : ០៤៤/០០៧/២០០១

ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០០១

សេចក្តីសំរេច

លេខ : ០៤៥/០០៧/២០០១ កបធ.ច

ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០១

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៣០១ /០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញបណ្តឹងរបស់អ្នកតំណាងរាស្ត្រ ១៥ រូប ស្នើសុំបកស្រាយមាត្រា ១២១ នៃព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញទទួលបាននៅថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០០១

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា ពាក្យបណ្តឹងលេខ ១៩/០១ ខសរ ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០១ របស់អ្នកតំណាងរាស្ត្រទាំង ១៥រូប មានមូលហេតុច្បាស់លាស់ និង អនុលោមតាមមាត្រា ១៣៦ ថ្មី មាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៨ នៃព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលពាក្យបណ្តឹងនោះមកពិភាក្សាបាន។

- យល់ឃើញថា ក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសថា ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នេះ ស្របនឹងរដ្ឋធម្មនុញ្ញរួចហើយ តាមសេចក្ដីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ ០៤២ /00៤ /២០០១ កបធ.ច ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០១ ។
- យល់ឃើញថា "**បញ្ជីបេក្ខជនដំបូង**" ( *មាត្រា ១១៦ និង មាត្រា ១១៧ នៃព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់* ) គឺជាបញ្ជីបេក្ខជន ដែលមិនទាន់ទៅជា "**បញ្ជីបេក្ខជនផ្លូវការ**" ដូច្នេះក្នុងរយៈពេលដែលមិនទាន់ទៅជា "**បញ្ជីបេក្ខជនផ្លូវការ**" ការបំពេញលក្ខខណ្ឌដែលខ្វះខាត ត្រូវតែអាចធ្វើទៅបាន ។ ករណីនៃមាត្រា ១២១ នៃព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ គឺស្ថិតនៅក្នុងដំណាក់កាលនៃ "**បញ្ជីបេក្ខជនដំបូង**" នៅឡើយ ។ គោលការណ៍នៃការកែតម្រូវចំណុចខ្វះខាត ឬ ការផ្លាស់ប្ដូរបេក្ខជន ត្រូវតែអនុវត្តបានចំពោះមាត្រា ១២១ ។ ម្យ៉ាងទៀត ក្នុងច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នេះ ក៏ពុំមានបទបញ្ញត្តិត្រង់ណា ហាមមិនឱ្យធ្វើការបំពេញបន្ថែម ឬ ផ្លាស់ប្ដូរបេក្ខជន ដែលត្រូវប្រជាពលរដ្ឋប្ដឹងជំទាស់នោះដែរ ។

# សំរេច

**មាត្រា ១** : យោងតាមមូលបទខាងលើ ក្នុងគ្រប់ដំណាក់កាលនៃ "**បញ្ជីបេក្ខជនដំបូង**" ការកែតម្រូវចំណុចខ្វះខាត ឬ ការផ្លាស់ប្ដូរបេក្ខជនដែលប្រជាពលរដ្ឋបានប្ដឹងជំទាស់ ត្រូវធ្វើបានជានិច្ច គឺរួមទាំងដំណាក់កាលនៃករណី ដែលមានចែងក្នុងមាត្រា ១២១ នៃព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ២** : សេចក្ដីសំរេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្ដីសំរេចស្ថាពរបិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០១

**ច.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ជា ស៊ីម

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១០៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបំបែកនាយកដ្ឋានអាស៊ី ប៉ាស៊ីហ្វិក ក្រៅពីអាស៊ាន នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជានាយកដ្ឋានអាស៊ីទី១និងនាយកដ្ឋានអាស៊ីទី២

-----×××-----

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

# សម្រេច

**មាត្រា១.-**

ត្រូវបានបំបែកនាយកដ្ឋានអាស៊ី ប៉ាស៊ីហ្វិក ក្រៅពីអាស៊ាន នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាពីរនាយកដ្ឋានគឺ ÷

- នាយកដ្ឋាន អាស៊ី ទី១
- នាយកដ្ឋាន អាស៊ី ទី២ ។

**មាត្រា២.-**

នាយកដ្ឋាន អាស៊ី ទី១ មានភារកិច្ច ÷

- តាមដាននិងធ្វើការងារនយោបាយនិងការងារសហប្រតិបត្តិការទ្វេភាគីជាមួយបណ្តាប្រទេស ដែលជាសមាជិកសមាគមប្រជាជាតិអាស៊ី អាគ្នេយ៍ អាស៊ាន ដោយសហការជិតស្និទ្ធ ជាមួយស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់អោយ ។

នាយកដ្ឋាន អាស៊ី ទី១ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

**មាត្រា៣.-**

នាយកដ្ឋាន អាស៊ី ទី២ មានភារកិច្ច ÷

- តាមដាន និងធ្វើការងារនយោបាយ និងការងារសហប្រតិបត្តិការទ្វេភាគីជាមួយបណ្តាប្រទេសអាស៊ីទាំងអស់ដែលមិនមែនជាសមាជិកសមាគមប្រជាជាតិអាស៊ី អាគ្នេយ៍ អាស៊ាន ដោយសហការជិតស្និទ្ធជាមួយស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់អោយ ។

នាយកដ្ឋាន អាស៊ី ទី២ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធានមួយនទ្បរជាជំនួយការតាមការចាំបាច់ ។

**មាត្រា៤.-**

ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពចំណុះនាយកដ្ឋានអាស៊ីទី១ និង នាយកដ្ឋានអាស៊ីទី២ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

មាត្រា៥.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៦.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ពាក់ពន្ធ័ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងការបរទេស

និងសហប្រតិបត្តិការអន្តរជាតិ

ហោ ណាំហុង

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ** ១០៦ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការធានារ៉ាប់រង

******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី២១ខែកញ្ញាឆ្នាំ២០០១

# សំរេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

ការធានារ៉ាប់រងដែលប្រើនៅក្នុងអនុក្រឹត្យនេះសំដៅលើការធ្វើកិច្ចសន្យាធានារ៉ាប់រងមួយដែលក្នុងនោះ អ្នកត្រូវបានធានារ៉ាប់រង នៅពេលចុះកិច្ចសន្យា ត្រូវបង់បុព្វលាភរ៉ាប់រងឱ្យទៅក្រុមហ៊ុនធានារ៉ាប់រង ហើយក្រុមហ៊ុនធានារ៉ាប់រងក៏ត្រូវធ្វើសំណងដល់ការខូចខាត និងការបាត់បង់ទ្រព្យសម្បត្តិដែលបង្កឡើងដោយគ្រោះថ្នាក់ ឬត្រូវធ្វើសំណងនៅពេលដែលអ្នកត្រូវបានធានារ៉ាប់រង ស្លាប់ របួស ពិការ មានជំងឺ ឬនៅពេលដែលភាគីទាំងសងខាងបានឈានដល់កាលកំណត់នៃការព្រមព្រៀងគ្នានោះ ។

**មាត្រា ២ .-**

អនុក្រឹត្យនេះអនុវត្តចំពោះអាជីវកម្មធានារ៉ាប់រងទាំងអស់ ដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣ .-**

ក្នុងប្រតិបត្តិការធានារ៉ាប់រងរបស់ខ្លួន រាល់ក្រុមហ៊ុនធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង និងជើងសាធានារ៉ាប់រងត្រូវគោរពតាមគោលការណ៍ប្រកួតប្រជែងត្រឹមត្រូវ ដោយអនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ។

**មាត្រា ៤ .-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងនិងត្រួតពិនិត្យលើអាជីវកម្មធានារ៉ាប់រង ដោយអនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ។

# ជំពូកទី២
# កិច្ចសន្យាធានារ៉ាប់រង
## ផ្នែកទី ១
## បែបបទទូទៅ

**មាត្រា ៥ .-**

ភាគីនៃកិច្ចសន្យាធានារ៉ាប់រងរួមមាន :

១- អ្នកធានារ៉ាប់រង

២- អ្នកត្រូវបានធានារ៉ាប់រង

-អ្នកធានារ៉ាប់រងសំដៅលើក្រុមហ៊ុនធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង និងជើងសារធានារ៉ាប់រង ។

-អ្នកត្រូវបានធានារ៉ាប់រងសំដៅលើបុគ្គលជាអ្នកជាប់កិច្ចសន្យាជាមួយអ្នកធានារ៉ាប់រង ។

**មាត្រា ៦ .-**

អ្នកត្រូវបានធានារ៉ាប់រងមានកាតព្វកិច្ច :

១- បង់បុព្វលាភរ៉ាប់រងជូនក្រុមហ៊ុនធានារ៉ាប់រងគ្រប់ចំនួនតាមការព្រមព្រៀងគ្នា ។

២- ជូនដំណឹងដល់ក្រុមហ៊ុនធានារ៉ាប់រងឱ្យបានឆាប់រហ័សបំផុត ពេលមានហានិភ័យកើតឡើង។

៣- សហការផ្តល់ពត៌មាននិងឯកសារដែលពាក់ព័ន្ធដល់ហានិភ័យ តាមសំណូមពររបស់ក្រុមហ៊ុនធានារ៉ាប់រង ។

**មាត្រា ៧ .-**

ក្រុមហ៊ុនធានារ៉ាប់រងមានកាតព្វកិច្ច :

១- ធ្វើសំណងចំពោះការខូចខាតឬការបាត់បង់ នៅពេលមានហានិភ័យកើតឡើងបណ្តាលមកពីមូលហេតុចៃដន្យ គ្រោះថ្នាក់ធម្មជាតិ និងពីរាល់មូលហេតុដែលមិនមែនជាអំពើចេតនារបស់អ្នកត្រូវបានធានារ៉ាប់រង ។

២- ធ្វើសំណងត្រឹមត្រូវតាមពេលវេលាកំណត់ តាមទំហំនៃការខូចខាតជាក់ស្តែង និងតាមទឹកប្រាក់ធានារ៉ាប់រង ។

**មាត្រា ៨ .-**

ដើម្បីចុះកិច្ចសន្យាធានារ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រងត្រូវដាក់ពាក្យស្នើសុំធានារ៉ាប់រង ឬធ្វើប្រតិវេទន៍ដោយផ្ទាល់នៅក្រុមហ៊ុនធានារ៉ាប់រង ឬតាមរយៈភ្នាក់ងារធានារ៉ាប់រង ។ ផ្អែកលើសំណើ ឬប្រតិវេទន៍នេះ ក្រុមហ៊ុនធានារ៉ាប់រងចាត់ការឱ្យចុះបំពេញនៅក្នុងប័ណ្ណសន្យារ៉ាប់រង ដែលតំរូវឱ្យខ្លួនទទួលធ្វើសំណងលើការខូចខាតដែលអាចនឹងកើតមានដោយថាហេតុ ។

ប័ណ្ណសន្យារ៉ាប់រងគឺជាឯកសារផ្ទុះបញ្ជាក់អំពីទំរង់នៃកិច្ចសន្យាធានារ៉ាប់រងដ៏ជាក់លាក់មួយ និងជាភស្តុតាងនៃកិច្ចសន្យានោះ ។ ឯកសារនេះត្រូវចុះហត្ថលេខាដោយក្រុមហ៊ុនធានារ៉ាប់រង ឬ ភ្នាក់ងារធានារ៉ាប់រង ។ នៅពេលចុះកិច្ចសន្យាធានារ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រងអាចពិភាក្សាជាមួយក្រុមហ៊ុនធានារ៉ាប់រង ដើម្បីជ្រើសរើសយកការចុះកិច្ចសន្យារយៈពេលខ្លីឬរយៈពេលវែងបានតាមការព្រមព្រៀងគ្នា ។

**មាត្រា ៩ .-**

ក្នុងករណីចាំបាច់និងបន្ទាន់ដែលមិនអាចធ្វើកិច្ចសន្យានិងចេញប័ណ្ណសន្យារ៉ាប់រងបាន នោះការធានារ៉ាប់រងអាចប្រព្រឹត្តទៅបាន ដោយប្រើ " កំណត់សំអាង " ជំនួសជាបណ្តោះអាសន្ន ។

កំណត់សំអាងគឺជាឯកសារដែលចេញដោយក្រុមហ៊ុនធានារ៉ាប់រង ឬ ភ្នាក់ងារធានារ៉ាប់រង ។ ឯកសារនេះជំនួសប័ណ្ណសន្យារ៉ាប់រងឬជាកិច្ចសន្យាបន្ថែម ក្នុងពេលរង់ចាំការចេញប័ណ្ណសន្យារ៉ាប់រងជាស្ថាពរ ។ នៅពេលចេញកំណត់សំអាង ភាគីទាំងសងខាងត្រូវចុះហត្ថលេខា ហើយអ្នកត្រូវបានធានារ៉ាប់រង ត្រូវបង់បុព្វលាភរ៉ាប់រង តាមការព្រមព្រៀងគ្នាដូចមានចែងក្នុងប័ណ្ណសន្យារ៉ាប់រងនោះស្រាប់ ។

**មាត្រា ១០ .-**

បណ្ណសន្យារ៉ាប់រងគឺជាតឹកតាងនៃកិច្ចសន្យាធានារ៉ាប់រងដែលធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយមានការចុះបំពេញនូវគោលបំណងរបស់អ្នកត្រូវបានធានារ៉ាប់រង ក្រោមការឯកភាពគ្នារវាងភាគីទាំងសងខាងនៃកិច្ចសន្យា ។

ល័ក្ខខ័ណ្ឌនៃបណ្ណសន្យារ៉ាប់រងត្រូវបានចែកចេញជាពីរផ្នែកចំបង។ គឺ ល័ក្ខខ័ណ្ឌទូទៅ និងល័ក្ខខ័ណ្ឌដោយឡែក :

១- ល័ក្ខខ័ណ្ឌទូទៅគឺជាឯកសារដែលមានកំណត់នូវគោលការណ៍សំខាន់ពីរ ស្តីអំពី :

ក- ប្រភេទហានិភ័យដែលត្រូវបានទទួលធានារ៉ាប់រងឱ្យ

ខ- ប្រភេទហានិភ័យដែលមិនត្រូវបានទទួលធានារ៉ាប់រងឱ្យ

២- ល័ក្ខខ័ណ្ឌដោយឡែក ហៅថា " វិញ្ញាបនប័ត្រធានារ៉ាប់រង " គឺជាឯកសារដែលមានការចុះបំពេញនូវសំណូមពរដោយឡែករបស់អ្នកត្រូវបានធានារ៉ាបរង តាមការប្រកាសនៅក្នុងពាក្យស្នើសុំធានារ៉ាប់រងរបស់ខ្លួន ដែលត្រូវមានហត្ថលេខាពីក្រុមហ៊ុន ធានារ៉ាប់រង ។

**មាត្រា ១១ .-**

ការបង់បុព្វលាភរ៉ាប់រងចំពោះហានិភ័យណាមួយគឺជាកាតព្វកិច្ចទីមួយរបស់អ្នកត្រូវ បានធានារ៉ាប់រង ។ បុព្វលាភរ៉ាប់រងត្រូវបង់ត្រឹមត្រូវតាមរយៈពេលធានា និងតាមចំនួនទឹកប្រាក់ធានារ៉ាប់រងសរុប ដោយគិតផ្អែកលើមូលដ្ឋាននៃតារាងបុព្វលាភរ៉ាប់រងរបស់ក្រុមហ៊ុននីមួយ។ ។

ក្នុងការបង់បុព្វលាភ អ្នកត្រូវបានធានារ៉ាប់រងអាចពិភាក្សាហើយព្រមព្រៀងជាមួយក្រុមហ៊ុនធានារ៉ាប់រង ដើម្បីធ្វើការបង់តែមួយលើក ឬច្រើនលើកបាន ។

**មាត្រា ១២ .-**

ក្នុងករណីដែលមានបំណងសុំបញ្ឈប់ការធានារ៉ាប់រងមុនកាលកំណត់ អ្នកត្រូវបានធានារ៉ាប់រងសាមីចាំបាច់ត្រូវជូនដំណឹងឱ្យក្រុមហ៊ុនធានារ៉ាប់រងរបស់ខ្លួនបានដឹងមុន ចំនួនដប់ថ្ងៃយ៉ាងតិច ។ ផ្អែកលើមូលហេតុសមស្រប ក្រុមហ៊ុនធានារ៉ាប់រងនឹងបង្វិលសងវិញចំនួនកៅសិបភាគរយ (៩០ %) នៃបុព្វលាភរ៉ាប់រងដែលនៅសល់ ។

ᴴᴸ·ᴸᴸ

ក្នុងករណីសុំបញ្ឈប់ការធានារ៉ាប់រងក្រោយពេលមានហានិភ័យកើតឡើង ហើយក្រុមហ៊ុនបានទូទាត់សំណងរួចហើយនោះ បុព្វលាភរ៉ាប់រងចំពោះរយៈពេលដែលនៅសល់មិនត្រូវបានក្រុមហ៊ុនធានារ៉ាប់រងបង្វិលសងវិញឡើយ ។

**មាត្រា ១៣ .-**

ក្នុងករណីសុំផ្អាកសកម្មភាពដើម្បីធ្វើការជួសជុលធំ អ្នកត្រូវបានធានារ៉ាប់រងសាមីចាំបាច់ត្រូវជូនដំណឹងដល់ក្រុមហ៊ុនធានារ៉ាប់រងរបស់ខ្លួនជាមុន ចំនួនដប់ថ្ងៃយ៉ាងតិច ។ ក្រុមហ៊ុនធានារ៉ាប់រងនឹងទូទាត់សងវិញ បន្ទាប់ពីពេលចាប់ដំណើរការឡើងវិញ នូវចំនួនកៅសិបភាគរយ ( ៩០% ) នៃបុព្វលាភរ៉ាប់រងសំរាប់រយៈពេលដែលបានផ្អាក ។

**មាត្រា ១៤ .-**

ក្នុងករណីដែលអ្នកត្រូវបានធានារ៉ាប់រងធនក្ស័យមុនកាលកំណត់ដែលចែងក្នុងកិច្ចសន្យាធានារ៉ាប់រង ចាំបាច់ត្រូវមានការជូនដំណឹងមកក្រុមហ៊ុនធានារ៉ាប់រង នៅក្នុងរយៈពេលដប់ថ្ងៃយ៉ាងយឺតបំផុត មុនការប្រកាសធនក្ស័យតាមរយៈលិខិតអនុសិដ្ឋឬលិខិតជូនដំណឹងដែលត្រូវបញ្ជាក់តបវិញច្បាស់លាស់ពីការបានទទួល ។ ក្រុមហ៊ុនធានារ៉ាប់រងនឹងបង្វិលសងវិញចំនួន កៅសិបភាគរយ ( ៩០% ) នៃបុព្វលាភរ៉ាប់រងដែលនៅសល់ ។

**មាត្រា ១៥ .-**

មានតែកិច្ចសន្យាបន្ថែមសំរាប់បន្តការធានារ៉ាប់រងទេ ដែលត្រូវបង់បុព្វលាភរ៉ាប់រងសមស្របតាមរយៈពេលដែលត្រូវបន្តនោះ ។ ចំពោះកិច្ចសន្យាបន្ថែមផ្សេងៗទៀត អ្នកត្រូវបានធានារ៉ាប់រងគ្រាន់តែបង់ជូនក្រុមហ៊ុនធានារ៉ាប់រង នូវថ្លៃកិច្ចសន្យាបន្ថែមតាមការកំណត់ប៉ុណ្ណោះ ។

**មាត្រា ១៦ .-**

ចំពោះករណីដែលអ្នកត្រូវបានធានារ៉ាប់រងឬជនរងគ្រោះបានទទួលរងការខូចខាត ការបាត់បង់ទ្រព្យសម្បត្តិ របួស ពិការ ឬបានបាត់បង់ជីវិត ត្រូវមានឯកសារពាក់ព័ន្ធចាំបាច់មួយចំនួនដែលបញ្ជាក់ការពិតពីអាជ្ញាធរមានសមត្ថកិច្ច ដើម្បីឱ្យក្រុមហ៊ុនធានារ៉ាប់រងប្រើប្រាស់ជាមូលដ្ឋាននៃការទូទាត់សំណងតាមការជាក់ស្តែង ។

**មាត្រា ១៧ .-**

នីតិវិធីដោះស្រាយធ្វើសំណងជំហានដំបូងត្រូវឈរលើមូលដ្ឋានចរចាសំរុះសំរួលដោយសន្តិវិធី រវាងក្រុមហ៊ុនធានារ៉ាប់រងនិងអ្នកត្រូវបានធានារ៉ាប់រង ឬ តតិយជនដែលរងគ្រោះ ។ ប្រសិនបើមិនអាចដោះស្រាយបានតាមរយៈការសំរុះសំរួលគ្នានោះទេ ទើបត្រូវពឹងពាក់អាជ្ញាកណ្តាល ដើម្បីដោះស្រាយបន្ត ។ ប្រសិនបើនៅតែមិនបានសំរេច ទើបភាគីដែលមិនសុខចិត្តអាចប្តឹងទៅតុលាការមានសមត្ថកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៨ .-**

ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់និងវាយតម្លៃការខូចខាត ពេលមានហានិភ័យណាមួយកើតឡើង ក្រុមហ៊ុនធានារ៉ាប់រងអាចចាត់អោយភ្នាក់ងារជំនាញរបស់ខ្លួនធ្វើកិច្ចការនោះនិងដោះស្រាយសំណងដោយផ្ទាល់ ឬដោយពឹងពាក់ក្រុមហ៊ុនត្រួតពិនិត្យហានិភ័យធានារ៉ាប់រងឯករាជ្យណាមួយ ដើម្បីឱ្យធ្វើជំនួស ។ ឯកសារនានាដែលក្រុមហ៊ុនត្រួតពិនិត្យនោះបានបង្កើតឡើង គឺជាមូលដ្ឋានសំរាប់ធ្វើការសម្រេចទូទាត់សំណងចំពោះការខូចខាត តាមការជាក់ស្តែង ។

**មាត្រា ១៩ .-**

ក្រុមហ៊ុនត្រួតពិនិត្យហានិភ័យធានារ៉ាប់រងគឺជានីតិបុគ្គលឯករាជ្យពីក្រុមហ៊ុនធានារ៉ាប់រង ហើយមានភារកិច្ចត្រួតពិនិត្យ ផ្ទៀងផ្ទាត់ វាយតំលៃការខូចខាត ពេលមានហានិភ័យធានារ៉ាប់រងកើតឡើងនិងសម្រេចចេញនូវឯកសារស្តីពីការវាយតំលៃការខូចខាត សំរាប់ជាមូលដ្ឋានឱ្យក្រុមហ៊ុនធានារ៉ាប់រងដោះស្រាយសំណង ។ ក្រុមហ៊ុនត្រួតពិនិត្យហានិភ័យធានារ៉ាប់រងធ្វើសកម្មភាពដោយទទួលថ្លៃឈ្នួលត្រួតពិនិត្យពីក្រុមហ៊ុនធានារ៉ាប់រង តាមការព្រមព្រៀងគ្នា ។

## ផ្នែកទី២

## ការធានារ៉ាប់រងទ្រព្យសម្បត្តិ

មាត្រា ២០ .-

ក្នុងករណីដែលអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ការធានារ៉ាប់រងត្រូវធ្លាក់ទៅលើទាយាទនៃវត្ថុដែលត្រូវបានធានារ៉ាប់រង ។ ទាយាទជាអ្នកទទួលមរតកបន្តនោះមានកាតព្វកិច្ចដូចអ្នកត្រូវបានធានារ៉ាប់រងដែរ ។ ផ្ដើមចេញពីល័ក្ខខ័ណ្ឌនេះ ទាយាទត្រូវជូនដំណឹងដល់ក្រុមហ៊ុនធានារ៉ាប់រងពីមរណភាពនៃអ្នកត្រូវបានធានារ៉ាប់រងពីខាងដើម ហើយសុំឱ្យធ្វើកិច្ចសន្យាបន្ថែមដើម្បីផ្ទេរការធានារ៉ាប់រងនោះមកឈ្មោះរបស់ខ្លួនជាផ្លូវការ ។ ប៉ុន្តែ ក្រុមហ៊ុនធានារ៉ាប់រងនិងទាយាទមានសិទ្ធិលុបជាស្ថាពរ នូវកិច្ចសន្យាធានារ៉ាប់រងពីខាងដើមនោះបាន ទៅតាមស្មារតីនៃអនុក្រឹត្យនេះ ។

មាត្រា ២១ .

ក្នុងករណីដែលវត្ថុក្នុងការធានារ៉ាប់រងត្រូវបានលក់បន្ត ការធានារ៉ាប់រងនោះអាចត្រូវបន្តទៅទៀតបាន នៅក្រោមលក្ខ័ខណ្ឌដែលម្ចាស់កម្មសិទ្ធិថ្មីបានជូនដំណឹងភ្លាមទៅក្រុមហ៊ុនធានារ៉ាប់រង ហើយសុំឱ្យធ្វើកិច្ចសន្យាបន្ថែម ដើម្បីផ្ទេរការធានារ៉ាប់រងមកឈ្មោះរបស់ខ្លួនជាផ្លូវការ ។

អ្នកលក់បន្តនៅតែមានកាតព្វកិច្ចបង់បុព្វលាភរ៉ាប់រងរហូត តាមកិច្ចសន្យា ប្រសិនបើគេមិនបានជូនដំណឹងពីការលក់បន្តនោះទៅក្រុមហ៊ុនធានារ៉ាប់រងរបស់ខ្លួន តាមរយៈលិខិតអនុសិដ្ឋ ឬ លិខិតជូនដំណឹងដែលត្រូវបញ្ជាក់តបវិញច្បាស់លាស់ពីការបានទទួលនោះទេ ។ ប៉ុន្តែក្រុមហ៊ុនធានារ៉ាប់រងនិងម្ចាស់កម្មសិទ្ធិថ្មី មានសិទ្ធិលុបជាស្ថាពរនូវកិច្ចសន្យាធានារ៉ាប់រងពីខាងដើម ។

មាត្រា ២២ .-

អ្នកដែលបានលក់បន្តនូវវត្ថុក្នុងការធានារ៉ាប់រង មានសិទ្ធិសុំដកយកវិញនូវបុព្វលាភរ៉ាប់រងចំនួនកៅសិបភាគរយ(៩០%)នៃទឹកប្រាក់សម្រាប់រយៈពេលដែលនៅសល់ ក្រោយពីបានជូនដំណឹងទៅក្រុមហ៊ុនធានារ៉ាប់រងរបស់ខ្លួន តាមរយៈលិខិតជាផ្លូវការដែលត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយឺតបំផុតម្ភៃបួនម៉ោងបន្ទាប់ពីការលក់ និងប្រសិនបើម្ចាស់កម្មសិទ្ធិថ្មីមិនបានមកសុំឱ្យធ្វើកិច្ចសន្យាបន្ថែម ដើម្បីផ្ទេរកិច្ចសន្យាពីខាងដើមមកឈ្មោះរបស់ខ្លួននៅឡើយទេ ។

# ផ្នែកទី ៣

## ការធានារ៉ាប់រងបុគ្គល

**មាត្រា ២៣ .-**

ប្រសិនបើអ្នកស្នើសុំធានារ៉ាប់រងបានប្រកាសអាយុមិនត្រឹមត្រូវពិតប្រាកដរបស់អ្នកត្រូវបានធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងអាចលុបចោលកិច្ចសន្យាធានារ៉ាប់រងរបស់ខ្លួន នៅក្នុងរយៈពេលតែពីរ(២) ឆ្នាំប៉ុណ្ណោះ ហើយបង្វិលបុព្វលាភរ៉ាប់រងជូនទៅអ្នកស្នើសុំធានារ៉ាប់រងវិញ បន្ទាប់ពីការកាត់កងជាមួយ សោហ៊ុយសំរាប់រយៈពេលធានារ៉ាប់រងកន្លងមក ។

**មាត្រា ២៤ .-**

ប្រសិនបើអ្នកស្នើសុំធានារ៉ាប់រងបានប្រកាសអាយុមិនត្រឹមត្រូវពិតប្រាកដរបស់អ្នកត្រូវបានធានារ៉ាប់រង ដើម្បីបង់បុព្វលាភរ៉ាប់រងតិចជាងបុព្វលាភរ៉ាប់រងដែលត្រូវបង់នោះ ក្រុមហ៊ុនធានារ៉ាប់រងមានសិទ្ធិតម្រូវឱ្យបង់បន្ថែម ឬមានសិទ្ធិធ្វើសំណងការខូចខាតសមស្រប តាមសមាមាត្រនៃបុព្វលាភរ៉ាប់រងដែលបានបង់និងបុព្វលាភរ៉ាប់រងដែលត្រូវបង់ ។

**មាត្រា ២៥ .-**

ប្រសិនបើអ្នកស្នើសុំធានារ៉ាប់រងបានប្រកាសអាយុរបស់អ្នកត្រូវបានធានារ៉ាប់រងមិនត្រឹមត្រូវពិតប្រាកដ ហើយបានបង់បុព្វលាភរ៉ាប់រងច្រើនជាងទឹកប្រាក់ដែលត្រូវបង់ ក្រុមហ៊ុនធានារ៉ាប់រងនឹងបង្វិលទឹកប្រាក់ដែលបានបង់លើសនោះ ជូនអ្នកស្នើសុំធានារ៉ាប់រងវិញ ។

**មាត្រា ២៦ .-**

កិច្ចសន្យាធានារ៉ាប់រងលើករណីមរណភាពត្រូវមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីសំណាក់អ្នកត្រូវបានធានារ៉ាប់រង ចំពោះទឹកប្រាក់ធានារ៉ាប់រង បើពុំនោះទេនឹងត្រូវចាត់

ហ

ទុកជាមោឃៈ ។ ប៉ុន្តែ ការធានារ៉ាប់រងអាយុជីវិតដែលត្រូវបានរៀបចំឡើងដោយឪពុក-ម្តាយសម្រាប់កូនជាអនីតិជននៅក្នុងបន្ទុក មិនស្ថិតក្រោមល័ក្ខខ័ណ្ឌខាងលើនេះឡើយ ។

**មាត្រា ២៧ .-**

បន្ទាប់ពីកិច្ចសន្យាត្រូវបានចុះហត្ថលេខារួចហើយ អ្នកស្នើសុំធានារ៉ាប់រងអាចបង់បុព្វលាភរ៉ាប់រងទាំងអស់តែមួយលើកឬច្រើនលើកបាន ជូនក្រុមហ៊ុនធានារ៉ាប់រង តាមការព្រមព្រៀងគ្នា ។

ក្នុងករណីដែលកិច្ចសន្យាបានចែងល័ក្ខខ័ណ្ឌឱ្យបង់បុព្វលាភរ៉ាប់រងច្រើនលើកនោះ អ្នកស្នើសុំធានារ៉ាប់រងត្រូវបង់លើកដំបូង នៅពេលដែលកិច្ចសន្យានោះចូលជាធរមាន ហើយនឹងត្រូវបង់លើកក្រោយៗទៀតត្រឹមត្រូវទៅតាមពេលវេលាដែលបានកំណត់ ។

**មាត្រា ២៨ .-**

អ្នកទទួលផលនៃការធានារ៉ាប់រងអាយុជីវិតត្រូវបានកំណត់ឈ្មោះជាមុន ដោយអ្នកត្រូវបានធានារ៉ាប់រងឬអ្នកស្នើសុំធានារ៉ាប់រង ។

អ្នកស្នើសុំធានារ៉ាប់រងត្រូវមានការយល់ព្រមជាមុនពីអ្នកត្រូវបានធានារ៉ាប់រង នៅពេលដែលអ្នកសុំធានារ៉ាប់រងនោះជាអ្នកកំណត់ឈ្មោះអ្នកទទួលផល ។

**មាត្រា ២៩ .-**

អ្នកត្រូវបានធានារ៉ាប់រងឬអ្នកស្នើសុំធានារ៉ាប់រងអាចកំណត់ឈ្មោះអ្នកទទួលផលតែម្នាក់ឬច្រើនអ្នកបាន ។

ប្រសិនបើអ្នកទទួលផលមានច្រើននាក់នោះ អ្នកត្រូវបានធានារ៉ាប់រងឬអ្នកស្នើសុំធានារ៉ាប់រងត្រូវកំណត់ឱ្យច្បាស់លាស់នូវលំដាប់នៃផលប្រយោជន៍និងចំណែកនៃផលប្រយោជន៍របស់ម្នាក់ៗ ។

ប្រសិនបើចំណែកនៃផលប្រយោជន៍មិនត្រូវបានកំណត់ជាលំដាប់លំដោយទេនោះ អ្នកទទួលផលទាំងអស់នឹងត្រូវទទួលដោយស្មើភាពគ្នា ។

អ្នកត្រូវបានធានារ៉ាប់រងឬអ្នកស្នើសុំធានារ៉ាប់រងអាចផ្លាស់ប្តូរឈ្មោះអ្នកទទួលផលបាន ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ក្រុមហ៊ុនធានារ៉ាប់រងរបស់ខ្លួន ។

ក្រុមហ៊ុនធានារ៉ាប់រង ក្រោយពីបានទទួលដំណឹងជាលាយលក្ខណ៍អក្សរស្តីពីការផ្លាស់ប្តូរឈ្មោះអ្នកទទួលផលហើយ ត្រូវចុះឈ្មោះអ្នកទទួលផលថ្មីនោះ នៅលើប័ណ្ណសន្យារ៉ាប់រង ។

អ្នកស្នើសុំធានារ៉ាប់រងត្រូវមានការយល់ព្រមពីអ្នកត្រូវបានធានារ៉ាប់រងជាមុន មុននឹងធ្វើការផ្លាស់ប្តូរឈ្មោះអ្នកទទួលផល ។

# ជំពូកទី ៣

# ប្រភេទធានារ៉ាប់រងជាកាតព្វកិច្ច

## ផ្នែកទី ១

## ការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ឬការធានារ៉ាប់រងតតិយជន

**មាត្រា ៣១ .-**

ការធានារ៉ាប់រងតតិយជនយានយន្តមានគោលដៅសំខាន់គឺការធ្វើសំណងដល់ជនរងគ្រោះនៃគ្រោះថ្នាក់ចរាចរដែលបានទទួលរងរបួស ពិការ ស្លាប់ ឬ ខូចខាតទ្រព្យសម្បត្តិដែលបង្កឡើង ដោយយានយន្តគ្រប់ប្រភេទ ។

ប្រភេទយានយន្តដែលចាំបាច់ត្រូវមានធានារ៉ាប់រងតតិយជន រួមមាន :

- យានយន្តគ្រប់ប្រភេទដែលធ្វើអាជីវកម្មដឹកជញ្ជូនទំនិញ ដឹកជញ្ជូនអ្នកដំណើរ ដឹកជញ្ជូនភ្ញៀវទេសចរ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។
- យានយន្តគ្រប់ប្រភេទដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុន សហគ្រាស រោងចក្រ ។
- យានយន្តរបស់អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិនិងសមាគមនានា ។
- ឧបករណ៍លាយស៊ីម៉ង់ត៍ដែលធ្វើចលនាផ្លាស់ប្តូរទីកន្លែងដោយម៉ាស៊ីនផ្ទាល់ឬដោយអូសសណ្តោង ។
- ត្រីចក្រយានយន្តដែលប្រើប្រាស់សំរាប់ធ្វើអាជីវកម្មដឹកជញ្ជូនទំនិញ ឬដឹកអ្នកដំណើរ ។

**មាត្រា ៣២ .-**

កិច្ចសន្យារ៉ាប់រងទាំងឡាយដែលបានចែងនៅក្នុងមាត្រា ៣១ ត្រូវចេញដោយក្រុមហ៊ុនធានារ៉ាប់រងណាមួយដែលបានចុះបញ្ជីត្រឹមត្រូវនិងដែលបានទទួលអាជ្ញាប័ណ្ណពីស្ថាប័នមានសមត្ថកិច្ច ដើម្បីធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣៣ .-**

ការធានារ៉ាប់រងតតិយជនបដិសេធមិនធ្វើសំណងចំពោះម្ចាស់យានយន្ត អ្នកបើកបរ អ្នកទទួលបន្ទុកថែទាំយានយន្តនិងអ្នករស់នៅក្នុងបន្ទុករបស់ម្ចាស់យានយន្តផ្ទាល់ ដែលបានទទួលរងរបួស ពិការ ឬស្លាប់ នៅក្នុងហេតុការណ៍នៃគ្រោះថ្នាក់ចរាចរឡើយ ។ អ្នកទាំងអស់ខាងលើនេះត្រូវមានប័ណ្ណសន្យារ៉ាប់រងដោយឡែកទៀត ។

**មាត្រា ៣៤ .-**

ពេលមានគ្រោះថ្នាក់ចរាចរកើតឡើង ម្ចាស់យានយន្តឬអ្នកបើកបរត្រូវជូនដំណឹងភ្លាម តាមគ្រប់មធ្យោបាយ ដល់ក្រុមហ៊ុនធានារ៉ាប់រង ។ ក្រៅពីនោះ ត្រូវសហការផ្តល់ពត៌មាននិងផ្តល់ឯកសារ ដែលពាក់ព័ន្ធនឹងហេតុការណ៍គ្រោះថ្នាក់ ដើម្បីឱ្យក្រុមហ៊ុនធានារ៉ាប់រងដោះស្រាយសំណងតាមការជាក់ស្តែងបានឆាប់រហ័ស ។

**មាត្រា ៣៥ .-**

ក្រុមហ៊ុនធានារ៉ាប់រងដែលធានាភារៈទទួលខុសត្រូវយានយន្តប្រកបអាជីវកម្ម តាមផ្លូវគោកត្រូវដោះស្រាយសំណងជូនជនរងគ្រោះឱ្យបានឆាប់រហ័សបំផុត តាមនីតិវិធីដូចខាងក្រោម :

១-តតិយជនទាំងឡាយដែលបានអនុវត្តត្រឹមត្រូវតាមច្បាប់ចរាចរ ហើយបានទទួលរងគ្រោះដល់រូបរាងកាយឬទ្រព្យសម្បត្តិ ដោយសារយានយន្តប្រកបអាជីវកម្មលើផ្លូវគោកបង្កឡើង សុទ្ធតែត្រូវបានក្រុមហ៊ុនធានារ៉ាប់រងធ្វើសំណង ចំពោះរាល់ការខូចខាតអន្តរាយ នោះឱ្យទាន់ពេលវេលា និងសមស្រប ទៅតាមកម្រិតនៃការខូចខាត ។

២- ភាគីទាំងអស់ត្រូវព្យាយាមឱ្យមានការស្រុះស្រួលគ្នា ដោយធ្វើការបញ្ជាក់ជាលាយលក្ខណ៍អក្សរ អំពីការព្រមព្រៀងលើមូលហេតុគ្រោះថ្នាក់ និងបំពេញរបាយការណ៍ស្តីពីគ្រោះថ្នាក់នោះឱ្យបានគ្រប់គ្រាន់ និងសមស្រប ។

៣- បើគ្មានការព្រមព្រៀងគ្នាទេ ភាគីទាំងអស់ត្រូវទាក់ទងឱ្យមានអន្តរាគមន៍ ពីនគរបាលចរាចរ ដើម្បីឱ្យធ្វើកំណត់ហេតុអង្កេតគ្រោះថ្នាក់និងប្លង់គ្រោះថ្នាក់ ។ ផ្អែកលើមូលដ្ឋាននៃឯកសារទាំងពីរនេះ ភាគីទាំងអស់ត្រូវពិភាក្សាគ្នាលើការធ្វើសំណង។ ក្នុងករណីដែលគ្រោះថ្នាក់កើតឡើងនៅមូលដ្ឋានដាច់ស្រយាលដែលគ្មាននគរបាលចរាចរដើងគោកឈរជើងទេនោះ ម្ចាស់យានយន្ត ឬអ្នកបើកបរត្រូវទាក់ទងជាមួយរដ្ឋអំណាចមូលដ្ឋានដែលមានសមត្ថកិច្ច ដើម្បីឱ្យបញ្ជាក់លើរបាយការណ៍គ្រោះថ្នាក់នោះ ។

៤- ប្រសិនបើភាគីទាំងអស់នៅតែមិនអាចស្រុះស្រួលគ្នាបានទៀតនោះ ទើបភាគីដែលមិនសុខចិត្ត អាចប្តឹងទៅតុលាការនៅតំបន់កើតហេតុ ដើម្បីឱ្យដោះស្រាយតាមផ្លូវច្បាប់។

**មាត្រា ៣៦ .-**

ក្នុងខណៈដែលមានតម្រូវការពីក្រុមអាជ្ញាធរមានសមត្ថកិច្ច ម្ចាស់យានយន្តនីមួយៗត្រូវបង្ហាញវិញ្ញាបនប័ត្រធានារ៉ាប់រង ។

**មាត្រា ៣៧ .-**

ម្ចាស់យានយន្តប្រកបអាជីវកម្មដែលមានការធានារ៉ាប់រងតតិយជនរួចហើយ ត្រូវបិទលតាប័ត្រដែលក្រុមហ៊ុនធានារ៉ាប់រងចេញឱ្យ នៅកញ្ចក់យានយន្តផ្នែកខាងមុខ ។

**មាត្រា ៣៨ .-**

ការធានារ៉ាប់រងផ្លូវទឹក និងផ្លូវអាកាសនឹងត្រូវកំណត់ក្នុងអនុក្រឹត្យដោយឡែក ។

## ផ្នែកទី ២

## ការធានារ៉ាប់រងការដ្ឋាន

មាត្រា ៣៩ .-

ការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន មានសារៈសំខាន់ក្នុងកិច្ចការពារផលប្រយោជន៍របស់តតិយជនទាំងឡាយដែលរស់នៅជុំវិញការដ្ឋាន ឬធ្វើដំណើរឆ្លងកាត់ឬក្បែរការដ្ឋាន ។ គ្រោះថ្នាក់ទាំងឡាយ ទោះបីដល់រូបរាងកាយក្តី ឬចំពោះទ្រព្យសម្បត្តិក្តី របស់តតិយជន ដែលត្រូវបានបង្កឡើងដោយសកម្មភាពរបស់ការដ្ឋាន សុទ្ធតែស្ថិតនៅក្នុងភារៈទទួលខុសត្រូវរបស់ម្ចាស់ការដ្ឋាន អ្នកម៉ៅការ ឬអ្នកម៉ៅការបន្ត ។

មាត្រា ៤០ .-

ប្រភេទការដ្ឋានដែលចាំបាច់ត្រូវមានការធានារ៉ាប់រងលើភារៈទទួលខុសត្រូវ រួមមានការដ្ឋានសាងសង់ ជួសជុល តម្លើង ទាំងអស់ ដែលទទួលខុសត្រូវដោយសហគ្រិន អ្នកម៉ៅការ ឬអ្នកម៉ៅការបន្ត លើកលែងតែនីតិបុគ្គលនៃនីតិសាធារណៈដែលទទួលបន្ទុកការងារសាងសង់ ជួសជុល ឬតម្លើង ដើម្បីជាផលប្រយោជន៍សាធារណៈ ។ ការលើកលែងទាំងមូលឬមួយផ្នែកអាចកំណត់ព្រមបានដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលអះអាងថាអាចមានលទ្ធភាពជួសជុលសងបានឆាប់រហ័សនិងគ្រប់គ្រាន់ នូវការខូចខាតទាំងឡាយ ។ រីឯការលោងសង់ឬជួសជុលកែលំអតូច ពោលដែលមិនតម្រូវឱ្យមានការអនុមតិលើគំរោងប្លង់ពី ស្ថាប័នមានសមត្ថកិច្ចទេនោះ គឺត្រូវបានលើកលែង ។

មាត្រា ៤១ .-

ប័ណ្ណសន្យារ៉ាប់រងដែលចែងនៅក្នុងមាត្រា ៤០ នៃអនុក្រឹត្យនេះ ត្រូវចេញដោយក្រុមហ៊ុនធានារ៉ាប់រងណាមួយដែលមានអាជ្ញាប័ណ្ណនិងដែលបានចុះបញ្ជីពាណិជ្ជកម្មត្រឹមត្រូវ ដើម្បីធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជា ។

## ផ្នែកទី ៣

## ការធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ

មាត្រា ៤២ .-

ការធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរមានសារៈសំខាន់ ដើម្បីការពារសិទ្ធិនិងផល

ប្រយោជន៍របស់អ្នកធ្វើដំណើរ តាមមធ្យោបាយដឹកជញ្ជូនអ្នកដំណើរនានា ។ ការធានារ៉ាប់រងប្រភេទនេះ តម្រូវឱ្យម្ចាស់មធ្យោបាយដឹកជញ្ជូនគោរពតាមបទដ្ឋាននៃការដឹកជញ្ជូន ពោលគឺមិនត្រូវផ្ទុកមនុស្សលើសពីចំនួនកៅអីដែលអនុញ្ញាត និងតម្រូវឱ្យថែទាំមធ្យោបាយដឹកជញ្ជូនរបស់ខ្លួនឱ្យបានល្អជាប្រចាំ ។

**មាត្រា ៤៣ .-**

មធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទដែលមានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មដឹកជញ្ជូនអ្នកដំណើរនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែមានការធានារ៉ាប់រងលើភារៈទទួលខុសត្រូវចំពោះអ្នកដំណើរតាមមធ្យោបាយដឹកជញ្ជូនរបស់ខ្លួន ។

**មាត្រា ៤៤ .-**

ការធានារ៉ាប់រងដែលបានចែងនៅមាត្រា ៤៣ នៃអនុក្រឹត្យនេះ ត្រូវបានចេញប័ណ្ណសន្យារ៉ាប់រង ដោយក្រុមហ៊ុនធានារ៉ាប់រងដែលមានអាជ្ញាប័ណ្ណ និងដែលបានចុះបញ្ជីពាណិជ្ជកម្មត្រឹមត្រូវដើម្បីធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤៥ .-**

ពេលមានគ្រោះថ្នាក់កើតឡើងពាក់ព័ន្ធនឹងអ្នកដំណើរ នៅពេលឡើងជិះ ពេលកំពុងជិះ ក៏ដូចពេលចុះពីមធ្យោបាយធ្វើដំណើរ អ្នកបើកបរឬម្ចាស់មធ្យោបាយដឹកជញ្ជូនត្រូវរាយការណ៍ដល់ក្រុមហ៊ុនធានារ៉ាប់រងរបស់ខ្លួនភ្លាម ទន្ទឹមនឹងនោះ ក៏ត្រូវរិះរកគ្រប់វិធីដើម្បីជួយសង្គ្រោះជនរងគ្រោះ ។

# ជំពូកទី ៤

# ក្រុមហ៊ុនធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង ជើងសាធានារ៉ាប់រង និងក្រុមហ៊ុនត្រួតពិនិត្យហានិភ័យធានារ៉ាប់រង

## ផ្នែកទី ១

### ក្រុមហ៊ុនធានារ៉ាប់រង

**មាត្រា ៤៦ .-**

ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់មិនអាចធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានទេ ប្រសិនបើក្រុមហ៊ុននោះ :

១-មិនមានអាជ្ញាប័ណ្ណដែលចេញដោយ :

ក- រាជរដ្ឋាភិបាលតាមសំណើរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងករណីជាក្រុមហ៊ុនធានារ៉ាប់រងរបស់រដ្ឋ ឬក្រុមហ៊ុនធានារ៉ាប់រងចំរុះរវាងរដ្ឋនិងឯកជន ដែលក្នុងនោះ រដ្ឋមានភាគហ៊ុនយ៉ាងតិចហាសិបមួយ (៥១) ភាគរយ ។

ខ- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងករណីជាក្រុមហ៊ុនធានារ៉ាប់រងឯកជន ។

២-មិនបានចុះបញ្ជីសំរាប់ប្រភេទធានារ៉ាប់រងណាមួយដូចមានចែងនៅមាត្រា ៤៦ នៃច្បាប់ ស្តីពីការធានារ៉ាប់រង ។

**មាត្រា ៤៧ .-**

ដើម្បីបានអាជ្ញាប័ណ្ណសំរាប់ធ្វើអាជីវកម្មធានារ៉ាប់រង នៅព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ត្រូវដាក់ពាក្យស្នើសុំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

នៅពេលដាក់ពាក្យនេះ អ្នកស្នើសុំត្រូវផ្តល់ឯកសារដូចតទៅ :

១- ពាក្យសុំជាលាយលក្ខណ៍អក្សរ ដែលក្នុងនោះមានបញ្ជាក់ពីប្រភេទអាជីវកម្មដើមទុនចុះបញ្ជី និងវិសាលភាពអាជីវកម្មរបស់ក្រុមហ៊ុនធានារ៉ាប់រងដែលនឹងត្រូវបង្កើតឡើងនោះ ។

២- លក្ខន្តិកៈរបស់ក្រុមហ៊ុនធានារ៉ាប់រងដែលនឹងដំណើរការ ។

៣- របាយការណ៍សេដ្ឋកិច្ចហិរញ្ញវត្ថុប៉ាន់ស្មាននៃបីការិយបរិច្ឆេទដំបូង ។

៤- បញ្ជីរាយនាមសមាជិកភាគហ៊ុន និងភាគហ៊ុនរបស់សមាជិកម្នាក់ៗ ។

៥- ជីវប្រវត្តិសង្ខេបរបស់អ្នកដឹកនាំ និងអ្នកគ្រប់គ្រងសំខាន់ៗ ដែលនឹងត្រូវតែងតាំង និង លិខិតថ្កោលទោសនៃបុគ្គលទាំងនោះ ។

៦- គោលការណ៍ និងគំរោងធ្វើប្រតិបត្តិការ ។

៧- ពត៌មានស្តីអំពីទីកន្លែងនានា ដែលក្រុមហ៊ុនកំណត់យកសំរាប់ធ្វើអាជីវកម្ម ។

៨- គំរូប័ណ្ណសន្យារ៉ាប់រង កិច្ចសន្យាបន្ថែម និងលិខិតបោះពុម្ពដែលសំរាប់ចែកផ្សាយដល់សាធារណជន ឬ សំរាប់ផ្សព្វផ្សាយ ទៅតាមប្រភេទប្រតិបត្តិការនីមួយៗ ។

៩- ឯកសារចាំបាច់ផ្សេងៗទៀតដែលតម្រូវដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទៅតាមប្រភេទអាជីវកម្មធានារ៉ាប់រងនីមួយៗ ។

**មាត្រា ៤៨ .-**

រាល់ពាក្យស្នើសុំអាជ្ញាប័ណ្ណរបស់ក្រុមហ៊ុនធានារ៉ាប់រងបរទេសត្រូវមានភ្ជាប់តាម ជាបន្ថែមពីលើឯកសារនៃចំណុច ទី១ ដល់ទី ៩ នៃមាត្រា ៤៧ ខាងលើ នូវឯកសារនិងពត៌មានផ្សេងទៀតដូចតទៅ :

១- តារាងតុល្យការ និងរបាយការណ៍លទ្ធផលនៃ ៣ ការិយបរិច្ឆេទចុងក្រោយ ។

២- ការតែងតាំងរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានគុណភាពជាអាណត្តិគាហក ។

៣- ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា ដែលក្រុមហ៊ុនបរទេសនោះមានសំណូមពរបោះទីតាំងរបស់ខ្លួន ។

៤- សេចក្តីបកប្រែវិញ្ញាបនប័ត្រចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដើមដែលបញ្ជាក់ថាក្រុមហ៊ុននោះបានធ្វើសកម្មភាពស្របច្បាប់ ។

**មាត្រា ៤៩ .-**

អាជ្ញាប័ណ្ណដំបូងដែលត្រូវបានផ្តល់ជូនក្រុមហ៊ុនធានារ៉ាប់រងគ្រប់ប្រភេទ មានសុពលភាពសំរាប់រយៈពេលប្រាំ (៥) ឆ្នាំ គិតចាប់ពីថ្ងៃចេញឱ្យប្រើប្រាស់ ។ រីឯអាជ្ញាប័ណ្ណឱ្យបន្តអាជីវកម្មមានសុពលភាពសំរាប់រយៈពេលបី (៣) ឆ្នាំ គិតចាប់ពីថ្ងៃចេញឱ្យដូចគ្នា ។ អាជ្ញាប័ណ្ណនេះ មិនអាចផ្ទេរ ឬលក់បានឡើយ ។

**មាត្រា ៥០ .-**

មុនពេលដែលអាជ្ញាប័ណ្ណអស់សុពលភាព ក្រុមហ៊ុនធានារ៉ាប់រងសាមីត្រូវដាក់ពាក្យស្នើសុំបន្តឡើងវិញ នៅក្នុងរយៈពេលមួយខែយ៉ាងយឺតបំផុត មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ នៅក្នុងរយៈពេលនេះ ក្រុមហ៊ុនធានារ៉ាប់រងនោះនៅតែមានសិទ្ធិធ្វើសកម្មភាព រហូតដល់ថ្ងៃដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យនិងសំរេចផ្តល់អាជ្ញាប័ណ្ណថ្មី ឬផ្អាកអាជីវកម្មដោយប្រការណាមួយ ។

**មាត្រា ៥១ .-**

ក្នុងករណីមានការក្លែងបន្លំឯកសារ ឬផ្តល់ពត៌មានមិនពិត ពាក់ព័ន្ធដល់ការស្នើសុំអាជ្ញាប័ណ្ណដំបូងឬសុំបន្តអាជ្ញាប័ណ្ណឡើងវិញ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសិទ្ធិបដិសេធការពិនិត្យ ផ្អាកសកម្មភាព និង/ឬដកហូតអាជ្ញាប័ណ្ណជាស្ថាពរ រហូតដល់ប្តឹងទៅតុលាការតាមកំហុសជាក់ស្តែង ចំពោះសាមីក្រុមហ៊ុនជាម្ចាស់សំណើ ។

**មាត្រា ៥២ .-**

ការបង់ប្រាក់សំរាប់ថ្លៃចេញអាជ្ញាប័ណ្ណដំបូងនិងអាជ្ញាប័ណ្ណបន្តឡើងវិញត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ៥៣ .-**

អនុលោមតាមមាត្រា ៤៨ នៃច្បាប់ស្តីពីការធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងដែលបង្កើតឡើងតាមច្បាប់ក្នុងស្រុកនិងសាខាក្រុមហ៊ុនធានារ៉ាប់រងបរទេសនីមួយៗ មុននឹងធ្វើសកម្មភាព ត្រូវបង្ហាញភស្តុតាងអំពីការបានបង់ប្រាក់ជំរះដើមទុនឬការបានទទួលទាយជ្ជទានដើមទុនលើកដំបូងរបស់ខ្លួន ធ្វើយ៉ាងណាឱ្យធានាបាននូវកាតព្វកិច្ចនៃការបានបង់ប្រាក់ដិកល់ក្នុងគណនីពិសេស នៅរតនាគារជាតិ និងការបានរក្សាទុកនូវចំនួនប្រាក់កំរិតសាធនភាព ក្នុងគណនីដោយឡែក នៅធនាគារពាណិជ្ជ ដែលមានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា និងនៅក្រោមល័ក្ខខ័ណ្ឌមួយចំនួន គឺ :

១- អំពីប្រាក់កំរិតសាធនភាព:

ក- ត្រូវកំរិតទៅតាមប្រភេទក្រុមហ៊ុនធានារ៉ាប់រងនីមួយៗ ដូចមានចែងនៅក្នុងមាត្រា ៥៦ នៃអនុក្រឹត្យនេះ ។

ខ- នៅពេលណាដែលប្រាក់កំរិតសាធនភាពនេះត្រូវបានប្រើប្រាស់ទៅសល់ក្រោមកំរិតជាផ្លូវការ សាមីក្រុមហ៊ុនធានារ៉ាប់រងត្រូវបំពេញបង្គ្រប់វិញ នៅក្នុងរយៈពេលយ៉ាងយឺតបំផុត ៣០ ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលសេចក្តីបង្គាប់ជាច់ខាតរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយប្រសិនបើពុំអនុវត្តបានដូច្នោះទេ សាមីក្រុមហ៊ុនត្រូវទទួលរងទណ្ឌកម្មតាមមាត្រា ៥៣ នៃច្បាប់ស្តីពីការធានារ៉ាប់រង ។

២- អំពីប្រាក់ដិកល់

ឃ ✓

ក- ត្រូវមានចំនួនយ៉ាងតិចស្មើនឹង ១០% នៃដើមទុនចុះបញ្ជី ។

ខ- ត្រូវបានរក្សាទុកជាអចិន្ត្រៃយ៍ក្នុងគណនីនៅរតនាគារជាតិ រហូតដល់បានបញ្ចប់ជាស្ថាពរនូវសកម្មភាពរបស់ក្រុមហ៊ុន ។

គ- មិនអាចត្រូវរាប់បញ្ចូលទៅក្នុងសាច់ប្រាក់ងាយស្រួល ដើម្បីគណនាភាពគ្រប់គ្រាន់នៃប្រាក់គិរិតសាធនភាព ដែលចែងនៅក្នុងចំណុច ១ នៃមាត្រា ៥៣ នេះបានឡើយ ។

ឃ- នៅពេលដែលប្រាក់ដិកល់នេះមានចំនួនតិចជាងគិរិតផ្លូវការ ដោយប្រការណាមួយ សាមីក្រុមហ៊ុនត្រូវបំពេញបង្គ្រប់វិញ នៅក្នុងរយៈពេល ៣០ ថ្ងៃ យ៉ាងយឺតបំផុត គិតចាប់ពីថ្ងៃបានទទួលសេចក្តីបង្គាប់ដាច់ខាតរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយប្រសិនបើពុំអនុវត្តបាដដូច្នោះទេ សាមីក្រុមហ៊ុនត្រូវរងទណ្ឌកម្មតាមមាត្រា ៥៣ នៃច្បាប់ស្តីពីការធានារ៉ាប់រង ។

៣- អំពីប្រាក់បំរើសកម្មភាពចរន្ត :

ក- ត្រូវស្ថិតនៅក្នុងការគ្រប់គ្រង និងការប្រើប្រាស់ផ្ទាល់របស់សាមីក្រុមហ៊ុន រាប់បញ្ចូលទាំងចំណូលបុព្វលាភរ៉ាប់រងផង ។

ខ- នៅពេលប្រើប្រាស់ប្រាក់នេះលើប្រតិបត្តិការធានារ៉ាប់រងមិនគ្រប់គ្រាន់ ទើបសាមីក្រុមហ៊ុនអាចប្រើប្រាស់ប្រាក់គិរិតសាធនភាពបន្ថែមទៀតបាន ។

**មាត្រា ៥៤ .-**

ដោយឡែក ចំពោះសាខានៃក្រុមហ៊ុនធានារ៉ាប់រងបរទេសដែលបោះទីតាំងនិងធ្វើសកម្មភាពនៅព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនមេត្រូវដាក់មកនូវសំណុំបែបបទសុំបើកសាខារបស់ខ្លួន ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចខាងក្រោម :

១- លក្ខន្តិកៈមានវិញ្ញាបនកម្ម ពីអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដើម ។

២- សេចក្តីសំរេចស្របតាមលក្ខន្តិកៈស្តីពីការបើកសាខានៅព្រះរាជាណាចក្រកម្ពុជា ។

៣- លិខិតអនុញ្ញាតពីអាជ្ញាធរអាណាព្យាបាលនៃប្រទេសដើម ស្តីពីការអនុញ្ញាតឱ្យសាមីក្រុមហ៊ុនបើក សាខានៅព្រះរាជាណាចក្រកម្ពុជា ។

៤- សេចក្តីសំរេចតែងតាំងបុគ្គលមានគុណវុឌ្ឍិ ដើម្បីឱ្យដឹកនាំសាខានៅព្រះរាជាណាចក្រកម្ពុជា ។

៥-របាយការណ៍ហិរញ្ញវត្ថុនៃបីការិយបរិច្ឆេទចុងក្រោយ ដោយមានវិញ្ញាបនកម្ម ពីសវនករឯករាជ្យនៃប្រទេសដើម ។

៦- លិខិតថ្កោលទោសចេញដោយប្រទេសដើម និងជីវប្រវត្តិសង្ខេបរបស់បុគ្គលដឹក នាំសាខានៅព្រះរាជាណាចក្រកម្ពុជា ។

៧- ឯកសារចាំបាច់ផ្សេងៗទៀតដែលតំរូវដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទៅតាមប្រភេទអាជីវកម្មនីមួយៗ ។

**មាត្រា ៥៥ .-**

ប្រាក់ដិកល់ដែលចែងនៅមាត្រា ៥៣ មាត្រា ៨៥ និងមាត្រា ៨៦ នៃអនុក្រឹត្យនេះ អាចជារូបិយប័ណ្ណឬប្រាក់រៀលនិង/ឬជាលិខិតធានារបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៥៦ .-**

ក្រុមហ៊ុនធានារ៉ាប់រងគ្រប់ប្រភេទត្រូវមានប្រាក់គ្រប់គ្រាន់ សំរាប់ធានាកិរិតសោធនភាព ។ កិរិតសាធនភាពគឺជាមូលនិធិនៅទំនេរត្រៀមដោះស្រាយបានិភ័យដែលកើតឡើងដោយថាហេតុ ឬដោះស្រាយសំណងដែលមានបរិមាណលើសពីមូលនិធិបំរុង ដែលក្រុមហ៊ុនបានបង្កើតឡើងតាមរយៈបុព្វលាភរ៉ាប់រង ។ កិរិតសាធនភាពនេះត្រូវបានកំណត់ជាអប្បបរមាទៅតាមសារៈសំខាន់នៃប្រភេទក្រុមហ៊ុនធានារ៉ាប់រងនីមួយៗដូចខាងក្រោម :

១- ក្នុងករណីដែលក្រុមហ៊ុនធានារ៉ាប់រងធ្វើប្រតិបត្តិការលើប្រភេទធានារ៉ាប់រង អាយុជីវិត ឬប្រភេទធានារ៉ាប់រងទូទៅ :

ក- ក្នុងឆ្នាំដំណើរការដំបូង :........................................ត្រូវមាន :៥០% នៃដើមទុនចុះបញ្ជីតាមច្បាប់

ខ- នៅពេលចំណូលបុព្វលាភរ៉ាប់រងសរុបដកចេញបុព្វលាភរ៉ាប់រងបន្តសរុបប្រចាំឆ្នាំមុននៅសល់ស្មើ ឬទាបជាង ៦៦.៥០០ លានរៀល :..........................ត្រូវមាន:១៣.៣០០ លានរៀល

គ- នៅពេលចំណូលបុព្វលាភរ៉ាប់រងសរុបដកចេញនូវបុព្វលាភរ៉ាប់រងបន្តសរុបប្រចាំឆ្នាំមុនមានចំនួនពី ៦៦.៥០០ លានរៀល ដល់ ៣៣២.៥០០ លានរៀល :....................................ត្រូវមាន:២០%

នៃចំណូលបុព្វលាភរ៉ាប់រងសរុបឆ្នាំមុន

ឃ- នៅពេលបុព្វលាភរ៉ាប់រងសរុបដកចេញនូវបុព្វលាភរ៉ាប់រងបន្តសរុប ប្រចាំឆ្នាំមុនមានចំនួនលើសពី ៣៣២.៥០០ លានរៀល ត្រូវមាន : ៦៦.៥០០ លានរៀល បូកនឹង ១០% នៃចំណែកបុព្វលាភដែល លើសពី ៣៣២.៥០០ លានរៀល

២- ក្នុងករណីដែលក្រុមហ៊ុនធានារ៉ាប់រងធ្វើប្រតិបត្តិការលើប្រភេទធានារ៉ាប់រង អាយុជីវិតនិងទូទៅនោះ ចំនួនទឹកប្រាក់កំរិតសាធនភាពនៅក្នុងចំណុច ១ នៃមាត្រានេះត្រូវមានមិនតិចជាង២៦.៦០០លានរៀលឡើយ ទោះនៅក្នុងករណីណាក៏ដោយ ។

**មាត្រា ៥៧ .-**

ក្រុមហ៊ុនធានារ៉ាប់រងរបស់រដ្ឋ ត្រូវមានការយល់ព្រមជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រសិនបើក្រុមហ៊ុននោះមានអាជ្ញាប័ណ្ណរួច ហើយមានបំណង :

១- ផ្លាស់ប្តូរប្រភេទធានារ៉ាប់រង ។

២- ផ្លាស់ប្តូរដើមទុនចុះបញ្ជី ។

៣- ផ្លាស់ប្តូរទីស្នាក់ការ ឬ ទីកន្លែងសាខារបស់ក្រុមហ៊ុន ។

៤- កែសំរួលវិសាលភាពអាជីវកម្ម ។

៥- បំបែក ឬ បញ្ចូលក្រុមហ៊ុន ។

៦- ផ្លាស់ប្តូរសមាជិកដែលមានភាគហ៊ុនលើសពី ១០% នៃដើមទុនរបស់ក្រុមហ៊ុន ។

៧-កែប្រែឬផ្លាស់ប្តូរល័ក្ខខ័ណ្ឌផ្សេងៗទៀតដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានកំណត់ ។

ក្នុងករណីដែលមានបំណងធ្វើការផ្លាស់ប្តូរប្រធានក្រុមប្រឹក្សាភិបាល ឬអគ្គនាយករបស់ខ្លួន ក្រុមហ៊ុនធានារ៉ាប់រងត្រូវរាយការណ៍ទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធ្វើការពិនិត្យល្អិតល្អន់លើលក្ខណៈសម្បត្តិរបស់បុគ្គលដែលនឹងត្រូវកាន់តំណែងជំនួស ។

**មាត្រា ៥៨.-**

ការបង្កើតសាខាឬការិយាល័យតំណាងរបស់ក្រុមហ៊ុនធានារ៉ាប់រងរដ្ឋដែលមានអាជ្ញាប័ណ្ណរួចហើយ នៅតាមតំបន់នានាក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុន ។

**មាត្រា ៥៩ .-**

វិសាលភាពអាជីវកម្មនៃក្រុមហ៊ុនធានារ៉ាប់រងរួមមាន :

១- ការធានារ៉ាប់រងទ្រព្យសម្បត្តិ ដែលរាប់បញ្ចូលទាំងអាជីវកម្មធានារ៉ាប់រងលើការខូចខាតបាត់បង់ទ្រព្យសម្បត្តិ ការធានារ៉ាប់រងលើភារៈទទួលខុសត្រូវ ការធានារ៉ាប់រងលើការសាងសង់ ការតម្លើង ការដឹកជញ្ជូនតាមផ្លូវគោក ផ្លូវអាកាស ផ្លូវសមុទ្រ ការធានារ៉ាប់រងលើការធ្វើដំណើរ លើតួនាវា លើតួយន្តហោះ និងការធានារ៉ាប់រងឥណទានពាណិជ្ជកម្ម ។

២- ការធានារ៉ាប់រងបុគ្គល ដែលរាប់បញ្ចូលទាំងអាជីវកម្មធានារ៉ាប់រងអាយុជីវិត ធានារ៉ាប់រងសុខភាព និងធានារ៉ាប់រងលើគ្រោះថ្នាក់ដល់បុគ្គលទាំងឡាយ ។

ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់អាចធ្វើសកម្មភាពធានារ៉ាប់រងបានតែនៅក្នុងដែនវិសាលភាពដែលមានចែងក្នុងអាជ្ញាប័ណ្ណតែប៉ុណ្ណោះ លើកលែងតែប្រភេទធានារ៉ាប់រងលើគ្រោះថ្នាក់និងគ្រោះថ្នាក់ពលកម្មដែលក្រុមហ៊ុនធានារ៉ាប់រងទាំងអស់អាចធ្វើសកម្មភាពបានដូចគ្នា ។

**មាត្រា ៦០ .-**

ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់អាចធ្វើប្រតិបត្តិការលើការធានារ៉ាប់រងបន្តបាន សំរាប់ :

១- ការធានារ៉ាប់រងបន្តចេញ និង

២- ការធានារ៉ាប់រងបន្តចូល ។

**មាត្រា ៦១ .-**

ការរក្សាទុកបុព្វលាភរ៉ាប់រង សំរាប់ឆ្នាំប្រតិបត្តិការនីមួយៗរបស់ក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើសកម្មភាពផ្នែកធានារ៉ាប់រងទ្រព្យសម្បត្តិ មិនអាចឱ្យលើសពីកំរិតបួន(៤)ដងនៃការបញ្ចូលគ្នានៃដើមទុនដែលកំពុងមានបច្ចុប្បន្ននិងមូលនិធិបំរុងឡើយ ។ ចំណែកដែលលើសនឹងត្រូវធ្វើការធានារ៉ាប់រងបន្ត ។

**មាត្រា ៦២ .-**

ការទទួលខុសត្រូវសំរាប់ឯកត្តាហានិភ័យនីមួយៗ របស់ក្រុមហ៊ុនធានារ៉ាប់រងដែលមានន័យថាជាការទទួលខុសត្រូវនៃការខូចខាតជាអតិបរមាបង្កឡើងដោយគ្រោះថ្នាក់នីមួយៗ មិនអាចលើសពីដប់

(១០) ភាគរយនៃការបញ្ចូលគ្នានៃដើមទុនដែលកំពុងមានបច្ចុប្បន្ននិងមូលនិធិបំរុងរបស់ក្រុមហ៊ុនធានារ៉ាប់រងឡើយ ។ ចំណែកដែលលើស ប្រសិនបើមាន នឹងត្រូវធ្វើការធានារ៉ាប់រងបន្ត ។

**មាត្រា ៦៣ .-**

នៅពេលដែលក្រុមហ៊ុនធានារ៉ាប់រងណាមួយមានតម្រូវការធានារ៉ាប់រងបន្តចេញ គឺត្រូវផ្តល់អាទិភាពជាមុន ចំពោះក្រុមហ៊ុនទាំងឡាយដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៦៤ .-**

ចំពោះកិច្ចសន្យាធានារ៉ាប់រងទាំងឡាយដែលមានទឹកប្រាក់ធានារ៉ាប់រងសរុបស្មើ ឬទាបជាងប្រាំរយពាន់(៥០០.០០០) ដុល្លារអាមេរិក ត្រូវតែធ្វើការធានារ៉ាប់រងបន្តជាមួយ ក្រុមហ៊ុនធានារ៉ាប់រងទាំងឡាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែកិច្ចសន្យាធានារ៉ាប់រងអាយុជីវិត ។

**មាត្រា ៦៥ .-**

នៅក្នុងរយៈពេលប្រាំមួយ(៦)ខែគិតចាប់ពីថ្ងៃបានទទួលអាជ្ញាប័ណ្ណ ប្រសិនបើសាមីក្រុមហ៊ុនធានារ៉ាប់រងមិនបានធ្វើការចុះបញ្ជីពាណិជ្ជកម្មទៅតាមច្បាប់ ដោយគ្មានមូលហេតុដែលអាចទទួលស្គាល់បានទេ អាជ្ញាប័ណ្ណរបស់ខ្លួននឹងត្រូវអស់សុពលភាពជាស្វ័យប្រវត្តិ ។

**មាត្រា ៦៦ .-**

ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ដែលបានទទួលអាជ្ញាប័ណ្ណឱ្យធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជា ត្រូវប្រើប្រាស់មូលនិធិបំរុងរបស់ខ្លួនដែលចែងនៅមាត្រា៥៦នៃអនុក្រឹត្យនេះ យ៉ាងតិចបំផុតចំនួនចិតសិបប្រាំភាគរយ (៧៥%) ជារៀងរាល់ឆ្នាំ សំរាប់ធ្វើវិនិយោគឡើងវិញ នៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៦៧ .-**

លើកលែងតែក្នុងអាជីវកម្មធានារ៉ាប់រងអាយុជីវិត ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ត្រូវធ្វើការធានារ៉ាប់រងបន្តទៅក្រុមហ៊ុនធានារ៉ាប់រងបន្តរបស់រដ្ឋចំនួនម្ភៃភាគរយ (២០%) យ៉ាងតិច នៃសេវាកម្ម

ធានារ៉ាប់រង ដែលក្រុមហ៊ុននោះបានចុះកិច្ចសន្យាតាមអត្រាបុព្វលាភរ៉ាប់រងទាបបំផុតរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលចែងនៅមាត្រា ៨៩ នៃអនុក្រឹត្យនេះ ។

**មាត្រា ៦៨ .-**

កាលបើពិនិត្យឃើញថា ក្រុមហ៊ុនធានារ៉ាប់រងណាមួយស្ថិតនៅក្នុងស្ថានភាពមិនអាចផ្តល់ការធានាគ្រប់គ្រាន់ចំពោះកិច្ចសន្យារបស់ខ្លួនឬមិនអាចរ៉ាប់រងបាននូវទំហំហានិភ័យដែលនឹងអាចកើតឡើងទេ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវក្រើនរំលឹកជាលាយលក្ខណ៍អក្សរ និងបង្គាប់ដាច់ខាតឱ្យសាមីក្រុមហ៊ុនធានារ៉ាប់រងកសាងកម្មវិធីហិរញ្ញវត្ថុច្បាស់លាស់ សំរាប់ស្តារក្រុមហ៊ុនរបស់ខ្លួនឱ្យមានប្រក្រតីភាពឡើងវិញ ។ ប្រសិនបើនៅតែគ្មានលទ្ធភាពស្តារបានតាមសេចក្តីបង្គាប់ដាច់ខាតខាងលើនេះទេ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសិទ្ធិហាមឃាត់ក្រុមហ៊ុនសាមីប្រើប្រាស់ទ្រព្យសកម្មរបស់ខ្លួន នៅព្រះរាជាណាចក្រកម្ពុជារហូតដល់មានការដោះស្រាយបានជាស្ថាពរ ។

**មាត្រា ៦៩ .-**

ក្រុមហ៊ុនធានារ៉ាប់រងទាំងឡាយ ក្រោយពីមានការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចផ្ទេរលើតម្លៃសរុបឬមួយភាគនៃសំពៀតបណ្ណសន្យារ៉ាប់រងមិនទាន់អស់សុពលភាព ដែលខ្លួនកាន់កាប់តាមកិច្ចសន្យាផ្តល់សេវាធានារ៉ាប់រង ទៅឱ្យក្រុមហ៊ុនធានារ៉ាប់រងណាមួយឬច្រើនទៀតដែលស្រុះស្រួលទទួលយក ។

**មាត្រា ៧០ .-**

ប្រសិនបើក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតណាមួយត្រូវបានរំលាយ ឬត្រូវបានប្រកាសធនក្ស័យស្របតាមច្បាប់ នោះកិច្ចសន្យាធានារ៉ាប់រងអាយុជីវិតនិងមូលនិធិបំរុងនៅក្នុងការកាន់កាប់របស់ខ្លួន ត្រូវផ្ទេរទៅឱ្យក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតផ្សេងទៀត ។ ក្នុងករណីដែលសាមីក្រុមហ៊ុនគ្មានលទ្ធភាពអនុវត្តវិធានការនេះបាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវចង្អុលបង្ហាញឈ្មោះក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតណាមួយ ឬច្រើនផ្សេងទៀត ដើម្បីឱ្យទទួលកិច្ចសន្យាធានារ៉ាប់រងទាំងនោះជាបន្ត ។

**មាត្រា ៧១ .-**

អាជ្ញាប័ណ្ណដែលត្រូវបានផ្តល់ឱ្យក្រុមហ៊ុនធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង ជើងសាធានារ៉ាប់រងនិងក្រុមហ៊ុនត្រួតពិនិត្យហានិភ័យធានារ៉ាប់រង អាចនឹងត្រូវដកហូតមកវិញបានគ្រប់ពេលវេលា កាលបើក្រុមហ៊ុននិមួយៗនោះ :

- មិនបានបំពេញគ្រប់គ្រាន់នូវល័ក្ខខ័ណ្ឌដែលតំរូវឱ្យអនុវត្តតាម
- មិនអាចធ្វើឱ្យបានសំរេចក្នុងរយៈពេលដែលបានយល់ព្រមចំពោះវិធានការគ្រោងទុកទាំងឡាយ តាមកម្មវិធីកែតម្រង់ឡើងវិញ
- ឬមួយមានការខ្វះខាតយ៉ាងធ្ងន់ធ្ងរក្នុងការបំពេញកាតព្វកិច្ច ដែលតម្រូវដោយបទបញ្ញាជាធរមាន ។

សាខាក្រុមហ៊ុនធានារ៉ាប់រងបរទេស ដែលកំពុងធ្វើសកម្មភាពនៅព្រះរាជាណាចក្រកម្ពុជា មានកាតព្វកិច្ចផ្តល់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទាន់ពេល នូវពតិមានសំខាន់ៗដែលពាក់ព័ន្ធដល់ការប្រែប្រួលដើមទុន សមាសភាពអ្នកចូលហ៊ុន និងធនក្ស័យនៃក្រុមហ៊ុនមេរបស់ខ្លួននៅបរទេស ។

ក្នុងករណីដែលមានការដកហូតអាជ្ញាប័ណ្ណពីក្រុមហ៊ុនធានារ៉ាប់រងមេនៅបរទេស ដោយអាជ្ញាធរមានសមត្ថកិច្ច ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវធ្វើការដកហូតអាជ្ញាប័ណ្ណដែលបានចេញឱ្យសាខារបស់ក្រុមហ៊ុនមេនោះ នៅក្នុងព្រះរាជាណាចក្រកម្ពុជាជាបន្ទាន់ភ្លាមដែរ ដើម្បីដាក់ឱ្យធ្វើការជំរះបញ្ជីបិទសាខានោះទៅតាមច្បាប់ ។

រាល់សេចក្តីសំរេចដកហូតអាជ្ញាប័ណ្ណ ឬផ្អាកសកម្មភាពត្រូវតែបញ្ជាក់ជាលាយលក្ខណ៍អក្សរអំពីមូលហេតុឱ្យបានច្បាស់លាស់ទៅសាមីក្រុមហ៊ុនមេ ។ សេចក្តីសំរេចដែលប្រកាសដកហូតអាជ្ញាប័ណ្ណត្រូវប្រកាសផ្សាយជាសាធារណៈក្នុងរាជកិច្ច ។

**មាត្រា ៧២ .-**

សេចក្តីសំរេចដកហូតអាជ្ញាប័ណ្ណជាស្ថាពរពីក្រុមហ៊ុនធានារ៉ាប់រងគ្រប់ប្រភេទ នឹងនាំទៅដល់ការរំលាយក្រុមហ៊ុននោះតាមផ្លូវច្បាប់ ។

**មាត្រា ៧៣ .-**

ក្រៅពីត្រូវអនុវត្តតាមច្បាប់ស្តីពីការធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងគ្រប់ប្រភេទ រាប់

បញ្ចូលទាំងសាខាក្រុមហ៊ុនធានារ៉ាប់រងបរទេសផង ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ពាក់ព័ន្ធទាំងឡាយស្តីពីការគ្រប់គ្រងក្រុមហ៊ុនពាណិជ្ជកម្ម ការគ្រប់គ្រងសហគ្រាសសាធារណៈ ការគ្រប់គ្រងក្រុមហ៊ុនចំរុះរដ្ឋនិងឯកជន ការគ្រប់គ្រងពន្ធដារ និងការគ្រប់គ្រងរដ្ឋបាលរបស់ព្រះរាជាណាចក្រកម្ពុជា ថែមទៀត។

បណ្ណសារជាតិ
ថ្ងៃទី______ខែ______ឆ្នាំ______

## ផ្នែកទី ២

## ភ្នាក់ងារធានារ៉ាប់រង ជើងសាធានារ៉ាប់រង

## ក្រុមហ៊ុនត្រួតពិនិត្យហានិភ័យធានារ៉ាប់រង

**មាត្រា ៧៤ .-**

ក្រុមហ៊ុនធានារ៉ាប់រងនីមួយៗ ត្រូវកំណត់ដែននៃការទទួលខុសត្រូវនិងការប្រព្រឹត្តិទៅព្រមទាំងល័ក្ខខ័ណ្ឌផ្សេងៗរបស់ភ្នាក់ងារធានារ៉ាប់រង និងជើងសាធានារ៉ាប់រងដែលធ្វើអាជីវកម្មលើវិស័យធានារ៉ាប់រងនៅក្នុងកិច្ចព្រមព្រៀងស្របតាមច្បាប់ ។

**មាត្រា ៧៥ .-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលមានបំណងធ្វើអាជីវកម្មលើវិស័យធានារ៉ាប់រង នៅព្រះរាជាណាចក្រកម្ពុជា ក្រោមទំរង់ជាភ្នាក់ងារធានារ៉ាប់រង ជើងសាធានារ៉ាប់រង ឬក្រុមហ៊ុនត្រួតពិនិត្យហានិភ័យធានារ៉ាប់រង ត្រូវដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណប្រកបអាជីវកម្មទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយភ្ជាប់ជាមួយនូវឯកសារនានា ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតំរូវឱ្យមាន និងត្រូវសុំចុះបញ្ជីពាណិជ្ជកម្មត្រឹមត្រូវទៅ តាមច្បាប់ ។

**មាត្រា ៧៦ .-**

គ្រប់ភ្នាក់ងារធានារ៉ាប់រង ជើងសាធានារ៉ាប់រង និងក្រុមហ៊ុនត្រួតពិនិត្យហានិភ័យធានារ៉ាប់រងមិនអាចធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជាបានទេ ប្រសិនបើមិនទាន់មានអាជ្ញាប័ណ្ណពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ៧៧ .-**

អាជ្ញាប័ណ្ណដែលត្រូវបានផ្តល់ឱ្យភ្នាក់ងារធានារ៉ាប់រងនិងក្រុមហ៊ុនត្រួតពិនិត្យហានិភ័យធានា

វ៉ាប់រង មានសុពលភាពសំរាប់រយៈពេលបី(៣)ឆ្នាំ គិតចាប់ពីថ្ងៃបានចេញឱ្យប្រើប្រាស់ ។ អាជ្ញាប័ណ្ណនេះមិនអាចផ្ទេរ ឬលក់ដោយប្រការណាមួយបានឡើយ ។

**មាត្រា ៧៨ .-**

អាជ្ញាប័ណ្ណដែលត្រូវបានផ្តល់ឱ្យជើងសាធានារ៉ាប់រង មានសុពលភាពសំរាប់រយៈពេលមួយ (១) ឆ្នាំ គិតចាប់ពីថ្ងៃបានចេញឱ្យប្រើប្រាស់ ។ អាជ្ញាប័ណ្ណនេះមិនអាចផ្ទេរ ឬលក់ដោយប្រការណាមួយបានឡើយ ។

**មាត្រា ៧៩ .-**

ភ្នាក់ងារធានារ៉ាប់រង ជើងសាធានារ៉ាប់រង និងក្រុមហ៊ុនត្រួតពិនិត្យហានិភ័យធានារ៉ាប់រងនីមួយៗ ត្រូវដាក់ពាក្យស្នើសុំបន្តអាជ្ញាប័ណ្ណឡើងវិញ នៅក្នុងរយៈពេលយ៉ាងយឺតបំផុតមួយខែមុនពេលអាជ្ញាប័ណ្ណរបស់ខ្លួនអស់សុពលភាព មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ នៅក្នុងរយៈពេល នេះសាមីក្រុមហ៊ុននៅតែបានសិទ្ធិធ្វើសកម្មភាពធម្មតា រហូតដល់ថ្ងៃទទួលបានអាជ្ញាប័ណ្ណថ្មីឬលិខិតជូនដំណឹងបដិសេធ ដោយមានឬដោយគ្មានល័ក្ខខ័ណ្ឌរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោយពីបានសិក្សាយ៉ាងល្អិតល្អន់នូវសំណុំបែបបទសុំបន្តអាជ្ញាប័ណ្ណឡើងវិញនោះ ។

**មាត្រា ៨០ .-**

ក្នុងករណីមានការក្លែងបន្លំឯកសារ ឬផ្តល់ពត៌មានមិនពិត ពាក់ព័ន្ធដល់ការស្នើសុំអាជ្ញាប័ណ្ណដំបូងឬសុំបន្តអាជ្ញាប័ណ្ណឡើងវិញ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសិទ្ធិបដិសេធការពិនិត្យ ផ្អាកសកម្មភាព និង/ឬដក ហូតអាជ្ញាប័ណ្ណជាស្ថាពរ រហូតដល់ប្តឹងទៅតុលាការតាមកំហុសជាក់ស្តែង ចំពោះសាមីក្រុមហ៊ុនជាម្ចាស់សំណើ ។

**មាត្រា ៨១ .-**

កម្រៃពីការចេញអាជ្ញាប័ណ្ណដំបូង និងអាជ្ញាប័ណ្ណបន្តអាជីវកម្ម ដែលជាបន្ទុកត្រូវបង់របស់ភ្នាក់ងារធានារ៉ាប់រង ជើងសាធានារ៉ាប់រង និងក្រុមហ៊ុនត្រួតពិនិត្យហានិភ័យធានារ៉ាប់រង ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាត្រា ៨២ .-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលមានអាជ្ញាប័ណ្ណធ្វើជាភ្នាក់ងារធានារ៉ាប់រងឱ្យក្រុមហ៊ុនធានារ៉ាប់រងណាមួយរួចហើយ ហើយដែលបានធ្វើជាភ្នាក់ងារឱ្យក្រុមហ៊ុនធានារ៉ាប់រងដទៃថែមទៀតនោះ ត្រូវតែជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអំពីការអនុវត្តរបស់ខ្លួន។

មាត្រា ៨៣ .-

ជើងសាធានារ៉ាប់រងដែលមានកំហុស នាំឱ្យខូចខាតឬបាត់បង់ផលប្រយោជន៍របស់អ្នកត្រូវបានធានារ៉ាប់រង ត្រូវទទួលខុសត្រូវធ្វើសំណងទៅតាមការខូចខាតជាក់ស្តែង ។

មាត្រា ៨៤ .-

ភ្នាក់ងារធានារ៉ាប់រង ជើងសាធានារ៉ាប់រង និង ក្រុមហ៊ុនត្រួតពិនិត្យហានិភ័យធានារ៉ាប់រងដែលបានទទួលអាជ្ញាប័ណ្ណរួចហើយ ត្រូវបើកការិយាល័យរបស់ខ្លួននៅព្រះរាជាណាចក្រកម្ពុជា ដែលមានអាស័យដ្ឋានច្បាស់លាស់នៅក្នុងអាជ្ញាប័ណ្ណដែលបានចេញឱ្យ ។ ប្រសិនបើត្រូវការផ្លាស់ប្តូរអាស័យដ្ឋាននៃការិយាល័យ ត្រូវមានលិខិតស្នើជាលាយលក្ខណ៍អក្សរទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីសុំការអនុញ្ញាតឱ្យបានជាមុន យ៉ាងយឺតបំផុតមួយខែមុនថ្ងៃរើផ្លាស់ប្តូរ ។

មាត្រា ៨៥ .-

ភ្នាក់ងារធានារ៉ាប់រង និងក្រុមហ៊ុនត្រួតពិនិត្យហានិភ័យធានារ៉ាប់រងទាំងអស់ដែលបានទទួលអាជ្ញាប័ណ្ណរួចហើយ ត្រូវដាក់ប្រាក់តំកល់ស្មើនឹងតម្លៃសមមូលមួយម៉ឺន ( ១០.០០០ ) ដុល្លារអាមេរិក នៅរតនាគារជាតិ នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៨៦ .-

ជើងសាធានារ៉ាប់រងទាំងអស់ដែលបានទទួលអាជ្ញាប័ណ្ណរួចហើយ ត្រូវដាក់ប្រាក់តំកល់ស្មើនឹងតម្លៃសមមូលប្រាំម៉ឺន (៥០.០០០) ដុល្លារអាមេរិកនៅរតនាគារជាតិ នៃព្រះរាជាណាចក្រកម្ពុជា។

បន្ថែមលើនេះ ជើងសាធានារ៉ាប់រងនិមួយៗ មុននឹងធ្វើអាជីវកម្ម ត្រូវមានការធានារ៉ាប់រងលើភារៈទទួលខុសត្រូវវិជ្ជាជីវៈដែលមានចំនួនទឹកប្រាក់ធានារ៉ាប់រងសមមូលនឹងប្រាំសែន (៥០០.០០០) ដុល្លារអាមេរិក ដោយត្រូវផ្ញើច្បាប់ថតចម្លងវិញ្ញាបនប័ត្រធានារ៉ាប់រងនោះមួយច្បាប់ ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីជាសក្ខីកម្ម ។

**មាត្រា ៨៧ .-**

ភ្នាក់ងារធានារ៉ាប់រង ជើងសាធានារ៉ាប់រង និងក្រុមហ៊ុនត្រួតពិនិត្យហានិភ័យធានារ៉ាប់រង ត្រូវចងក្រងវិធានគណនេយ្យច្បាស់លាស់ ដែលត្រូវមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុន ដើម្បីគ្រប់គ្រងចំណូល និងចំណាយក្នុងមុខវិជ្ជាជីវៈរៀងៗខ្លួន ប្រកបដោយភាពប្រាកដប្រជា ។

# ជំពូកទី ៥

## ការត្រួតពិនិត្យរបស់រដ្ឋ

**មាត្រា ៨៨ .-**

ការត្រួតពិនិត្យក្រុមហ៊ុនធានារ៉ាប់រងគ្រប់ប្រភេទ នៅព្រះរាជាណាចក្រកម្ពុជា គឺជាសមត្ថកិច្ចរបស់ក្រុមមន្ត្រីត្រួតពិនិត្យ ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចាត់តាំងឡើង ដោយផ្អែកលើសមត្ថភាពជំនាញនិងបទពិសោធន៍របស់ពួកគេ លើវិស័យនេះ ។

**មាត្រា ៨៩ .-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវដាក់ចេញនូវតារាងមួយស្តីពីតម្លៃទាបបំផុត សំរាប់អនុវត្តចំពោះហានិភ័យធំៗ សំដៅធានាលំនឹងនៃទីផ្សារ និងតំរង់ទិសនៃការប្រកួតប្រជែងក្នុងទីផ្សារ ។ តារាងតម្លៃទាបបំផុតនេះនឹងមិនអាចត្រូវយកទៅអនុវត្ត ចំពោះប្រភេទធានារ៉ាប់រងអាយុជីវិតឡើយ ។

តារាងតម្លៃទាបបំផុតដូចមានចែងនៅក្នុងវាក្យខ័ណ្ឌទីមួយនៃមាត្រា ៨៩ នេះ នឹងអាចត្រូវកែសំរួលបាន ទៅតាមសភាពការណ៍សេដ្ឋកិច្ច ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាត្រា ៩០ .-

ក្រុមហ៊ុនធានារ៉ាប់រងគ្រប់ប្រភេទត្រូវដាក់តម្កល់ទុកជាភស្តុតាង នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នូវគំរូពាក្យស្នើសុំធានារ៉ាប់រង ល័ក្ខខ័ណ្ឌទូទៅនៃប័ណ្ណសន្យារ៉ាប់រង គំរូវិញ្ញាបនប័ត្រធានារ៉ាប់រង និងឯកសារបោះពុម្ពផ្សេងៗទៀតដែលចាំបាច់ត្រូវចែកជូនអតិថិជន ឬត្រូវផ្សព្វផ្សាយ ។

ប្រសិនបើយល់ថាចាំបាច់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចតំរូវឱ្យមានការកែប្រែខ្លឹមសារលើឯកសារទាំងឡាយដែលរាយក្នុងវាក្យខ័ណ្ឌខាងលើនេះ ដែលត្រូវបានប្រើប្រាស់មិនសមស្របនៅក្នុងប្រតិបត្តិការធានារ៉ាប់រង ឬក្នុងមូលធនកម្មរបស់ក្រុមហ៊ុន ។

មាត្រា ៩១ .-

ប្រសិនបើមានការកែប្រែលក្ខន្តិកៈ សាមីក្រុមហ៊ុនធានារ៉ាប់រងត្រូវផ្ញើជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅក្នុងរយៈពេល១៥ថ្ងៃយ៉ាងយឺតបំផុត គិតចាប់ពីថ្ងៃធ្វើសេចក្តីសំរេចក្នុងមហាសន្និបាតវិសាមញ្ញរបស់ក្រុមហ៊ុន នូវអត្ថបទស្តីពីវិសោធនកម្មនៃលក្ខន្តិកៈនោះ និងឯកសារពាក់ព័ន្ធផ្សេងៗទៀត ។

ដើម្បីធានាឱ្យមានតម្លាភាពនៃការប្រកួតប្រជែងរបស់ខ្លួននៅក្នុងទីផ្សារធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងគ្រប់ប្រភេទត្រូវផ្ញើជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុន នូវតារាងតម្លៃទូទៅដែលខ្លួនត្រៀមយកទៅអនុវត្តជាមួយអតិថិជន ។

មាត្រា ៩២ .-

ក្រុមហ៊ុនធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង ជើងសាធានារ៉ាប់រង និងក្រុមហ៊ុនត្រួតពិនិត្យបាតុភូតហានិភ័យធានារ៉ាប់រងទាំងឡាយ ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យរបស់រដ្ឋ ត្រូវស្ថិតនៅក្រោមការរំពៃឃ្លាំមើលរបស់ក្រុមមន្ត្រីត្រួតពិនិត្យធានារ៉ាប់រងដែលតែងតាំងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ នៅគ្រប់កាលៈទេសៈ ជាបន្ថែមលើការត្រួតពិនិត្យតាមរយៈរបាយការណ៍ ក្រុមមន្ត្រីត្រួតពិនិត្យទាំងនោះអាចដឹកនាំការពិនិត្យផ្ទៀងផ្ទាត់នៅនឹងកន្លែង ចំពោះគ្រប់ប្រតិបត្តិការរបស់ក្រុមហ៊ុនធានារ៉ាប់រងនីមួយៗ ។

មាត្រា ៩៣ .-

រាល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលបានទទួលអាណត្តិឱ្យចុះកិច្ចសន្យា ឬគ្រប់គ្រងក្រុមហ៊ុនធានារ៉ាប់រងក្តី ឬភ្នាក់ងារធានារ៉ាប់រង ជើងសាធានារ៉ាប់រង និងក្រុមហ៊ុនត្រួតពិនិត្យហានិភ័យធានារ៉ាប់រងក្តី

សុទ្ធតែត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រុមមន្ត្រីត្រួតពិនិត្យធានារ៉ាប់រង ។ ក្រុមមន្ត្រីត្រួតពិនិត្យធានារ៉ាប់រងអាចផ្ទៀងផ្ទាត់ទិន្នន័យលេខនិងកិច្ចបញ្ជីកាគណនេយ្យ រាល់ឯកសារគណនេយ្យផ្សេងទៀត ទោះតាមវិធីសាមញ្ញឬតាមប្រព័ន្ធពត៌មានវិទ្យាស្ដ្រ និងលិខិតស្នាមគ្រប់ប្រភេទរបស់ក្រុមហ៊ុន ដែលចាំបាច់ដល់ការសិក្សាអង្កេតស្រាវជ្រាវ ។

**មាត្រា ៩៤ .-**

គ្រប់ក្រុមហ៊ុនធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង ជើងសាធានារ៉ាប់រង និងក្រុមហ៊ុនត្រួតពិនិត្យហានិភ័យធានារ៉ាប់រង ត្រូវប្រគល់ជូនមន្ត្រីត្រួតពិនិត្យធានារ៉ាប់រងដែលអនុវត្តភារកិច្ចនេះ នូវឯកសារនានាដែលត្រូវបានរៀបរាប់នៅមាត្រា៩៣នៃអនុក្រឹត្យនេះ និងបុគ្គលទាំងឡាយដែលមានការពាក់ព័ន្ធដើម្បីបង្កលក្ខណៈងាយស្រួលឱ្យការត្រួតពិនិត្យឬការផ្ទៀងផ្ទាត់អាចសំរេចទៅបានក្នុងតម្លាភាពនិងសច្ចភាពខ្ពស់ ។

មន្ត្រីត្រួតពិនិត្យធានារ៉ាប់រងត្រូវរាយការណ៍អំពីលទ្ធផលនៃការត្រួតពិនិត្យឬការផ្ទៀងផ្ទាត់ និងការកត់សំគាល់របស់ខ្លួន ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីមានវិធានការសមស្របទាន់ពេលទៅតាមកំហុសជាក់ស្ដែង ។

**មាត្រា ៩៥ .-**

ក្នុងរយៈពេលបីខែ ក្រោយពេលបញ្ចប់ការិយបរិច្ឆេទនីមួយៗ ក្រុមហ៊ុនធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង ជើងសាធានារ៉ាប់រង និងក្រុមហ៊ុនត្រួតពិនិត្យហានិភ័យធានារ៉ាប់រងនីមួយៗត្រូវផ្ញើជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នូវសេចក្ដីសំរេចរបស់មហាសន្និបាតសាមញ្ញ សេចក្ដីរាយការណ៍របស់ផ្ទៃការប្រតិបត្តិ សវនការគណនី ក្រុមប្រឹក្សាភិបាល និងរបាយការណ៍ហិរញ្ញវត្ថុ ព្រមទាំងឯកសារចាំបាច់ផ្សេងៗទៀតរបស់ក្រុមហ៊ុន ប្រចាំការិយបរិច្ឆេទដែលទើបចប់ទៅ ។

**មាត្រា ៩៦ .-**

នៅដើមខែនីមួយៗ ក្រុមហ៊ុនធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង ជើងសាធានារ៉ាប់រង និងក្រុមហ៊ុនត្រួតពិនិត្យហានិភ័យធានារ៉ាប់រងនិមួយៗ ត្រូវធ្វើស្ថិតិអាជីវកម្មក្នុងខែកន្លងទៅ ហើយផ្ញើជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីជារបាយការណ៍យ៉ាងទៀងទាត់ ។

**មាត្រា ៩៧ .-**

ក្រុមហ៊ុនធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង ជើងសាធានារ៉ាប់រង និងក្រុមហ៊ុនត្រួតពិនិត្យហានិភ័យធានារ៉ាប់រងត្រូវធ្វើស្ថិតិអាជីវកម្មរបស់ខ្លួន ហើយផ្ញើជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជារៀងរាល់ខែ ដោយត្រូវឆ្លុះបញ្ចាំងអំពី :

១-សំរាប់ការងារអាជីវកម្ម :

ក- ចំនួនប័ណ្ណសន្យារ៉ាប់រងដែលបានចេញជូនអតិថិជន ដោយបែងចែកតាមប្រភេទអាជីវកម្ម ។

ខ- ថ្ងៃ ខែ ឆ្នាំ ដែលប័ណ្ណសន្យារ៉ាប់រងនីមួយៗចាប់ផ្តើមមានប្រសិទ្ធិភាព ។

គ- ថ្ងៃ ខែ ឆ្នាំ ដែលប័ណ្ណសន្យារ៉ាប់រងនីមួយៗអស់សុពលភាព ។

ឃ- ចំនួនទឹកប្រាក់ធានារ៉ាប់រង ។

ង- អត្រាបុព្វលាភរ៉ាប់រង ។

ច ក៏រិតបញ្ចុះតម្លៃ ។

២-សំរាប់ការងារដោះស្រាយសំណង :

ក- ចំនួនប័ណ្ណសន្យារ៉ាប់រងដែលមានហានិភ័យកើតឡើង ។

ខ- ប្រភេទហានិភ័យដែលបានកើតឡើង និងចំនួនទឹកប្រាក់សំណងដែលបានដោះស្រាយរួចហើយ ។

គ- ប្រភេទហានិភ័យដែលបានកើតឡើងនិងចំនួនទឹកប្រាក់សំណងប៉ាន់ស្មានដែលមិនទាន់ដោះស្រាយ ។

## ជំពូកទី ៦

## ទោសប្បញ្ញត្តិ

**មាត្រា ៩៨ .-**

បុគ្គលណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៣១ មាត្រា ៤០ ឬ មាត្រា ៤៣ នៃអនុក្រឹត្យនេះត្រូវទទួលរងទណ្ឌកម្មតាមមាត្រា ៥២ នៃច្បាប់ស្តីពីការធានារ៉ាប់រង ។

**មាត្រា ៩៩ .-**

បុគ្គលណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៤៦ នៃអនុក្រឹត្យនេះ ត្រូវទទួលរងទណ្ឌកម្មតាមមាត្រា ៥៤ នៃច្បាប់ស្តីពីការធានារ៉ាប់រង ។

## ជំពូកទី ៧
## អន្តរប្បញ្ញត្តិ

**មាត្រា ១០០ .-**

ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមានតទៅ ម្ចាស់ការដ្ឋាន អ្នកម៉ៅការ ឬអ្នកម៉ៅការបន្តទាំងអស់ដូចមានចែងនៅក្នុងមាត្រា ៤០ នៃអនុក្រឹត្យនេះ ត្រូវតែមានការធានារ៉ាប់រងលើភារៈទទួលខុសត្រូវរបស់ខ្លួន ។ កិច្ចសន្យាធានារ៉ាប់រងប្រភេទនេះត្រូវចុះជាមួយក្រុមហ៊ុនធានារ៉ាប់រងណាមួយ ដែលមានអាជ្ញាប័ណ្ណឱ្យធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជា ដោយមិនអាចចុះជាមួយក្រុមហ៊ុនធានារ៉ាប់រងនៅក្រៅប្រទេសកម្ពុជាបានឡើយ ។

**មាត្រា ១០១ .-**

ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០២ តទៅ ម្ចាស់យានយន្តធ្វើអាជីវកម្មគ្រប់ប្រភេទដូចមានចែងនៅក្នុងមាត្រា ៣១ នៃអនុក្រឹត្យនេះ ត្រូវមានកាតព្វកិច្ចទិញការធានារ៉ាប់រងតតិយជនសំរាប់យានយន្តរបស់ខ្លួន ។ ប័ណ្ណសន្យារ៉ាប់រងប្រភេទនេះត្រូវទិញនៅក្រុមហ៊ុនធានារ៉ាប់រងណាមួយ ដែលមានអាជ្ញាប័ណ្ណឱ្យធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជា ដោយមិនអាចទិញពីក្រុមហ៊ុននៅក្រៅប្រទេសកម្ពុជាបានឡើយ ។

**មាត្រា ១០២ .-**

ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០២ តទៅ ម្ចាស់មធ្យោបាយដឹកជញ្ជូនអ្នកដំណើរគ្រប់ប្រភេទដូចមានចែងនៅមាត្រា ៤៣ នៃអនុក្រឹត្យនេះ ត្រូវមានការធានារ៉ាប់រងលើភារៈទទួលខុសត្រូវចំពោះអ្នកដំណើរតាមមធ្យោបាយដឹកជញ្ជូនរបស់ខ្លួន។ ប័ណ្ណសន្យារ៉ាប់រងប្រភេទនេះត្រូវទិញនៅក្រុម

ប៉ុនធានារ៉ាប់រងណាមួយដែលមានអាជ្ញាប័ណ្ណឱ្យធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជា ដោយមិនអាចទិញពីក្រុមហ៊ុននៅក្រៅព្រះរាជាណាចក្រកម្ពុជាបានឡើយ ។

# ជំពូកទី ៨

## អវសានបញ្ញត្តិ

មាត្រា ១០៣ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ព្រមទាំងគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ១០៤ .-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១០៥ .-

អនុក្រឹត្យនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១០៣
- កាលប្បវត្តិ - ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ២០០២

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា.
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី.
- យោងអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៦ ស្តីពីការកំណត់រយៈពេលបំរើការងារប្រចាំសប្តាហ៍របស់មន្ត្រីរាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា .
- តាមសំណើរបស់គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ លេខ ៣៥០/២០០១/គ.ប.ជ.អ ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ ២០០១ ។

**សំរេច**

**មាត្រា ១ :** អនុញ្ញាតិអោយមន្ត្រីរាជការ និយោជិត កម្មករ នៃព្រះរាជាណាចក្រកម្ពុជាទាំងអស់ បានឈប់សំរាកការងារប្រចាំឆ្នាំ ២០០២ តាមប្រតិទិនដូចខាងក្រោម :

| | | |
|---|---|---|
| - ថ្ងៃទី ០១ មករា | - ទិវាចូលឆ្នាំសកល | ឈប់ ០១ ថ្ងៃ |
| - ថ្ងៃទី ០៧ មករា | - ទិវាជ័យជំនះលើរបបប្រល័យពូជសាសន៍ | ឈប់ ០១ ថ្ងៃ |
| - ថ្ងៃទី ០៨ មីនា | - ទិវានារីអន្តរជាតិ | ឈប់ ០១ ថ្ងៃ |
| - ថ្ងៃទី ១៤-១៥-១៦ មេសា | - ទិវាចូលឆ្នាំប្រពៃណីជាតិ | ឈប់ ០៣ ថ្ងៃ |
| - ថ្ងៃទី ២៦ មេសា | - បុណ្យវិសាខបូជា | ឈប់ ០១ ថ្ងៃ |
| - ថ្ងៃទី ៣០ មេសា | - ព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័ល | ឈប់ ០១ ថ្ងៃ |
| - ថ្ងៃទី ០១ ឧសភា | - ទិវាពលកម្មអន្តរជាតិ | ឈប់ ០១ ថ្ងៃ |

| | | |
|---|---|---|
| - ថ្ងៃទី ០១ មិថុនា | - ទិវាកុមារអន្តរជាតិ | ឈប់ ០១ ថ្ងៃ |
| - ថ្ងៃទី ១៨ មិថុនា | ព្រះរាជពិធីបុណ្យចំរើនព្រះជន្មសម្តេចព្រះរាជអគ្គមហេសី នរោត្តម មុនិនាថ សីហនុ | ឈប់ ០១ ថ្ងៃ |
| - ថ្ងៃទី ២៤ កញ្ញា | - ទិវាប្រកាសរដ្ឋធម្មនុញ្ញ និងព្រះរាជពិធីគ្រងរាជសម្បត្តិជាថ្មី របស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ | ឈប់ ០១ ថ្ងៃ |
| - ថ្ងៃទី ០៥-០៦-០៧ តុលា | - បុណ្យភ្ជុំបិណ្ឌ | ឈប់ ០៣ ថ្ងៃ |
| - ថ្ងៃទី ២៣ តុលា | - ទិវាសន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីស | ឈប់ ០១ ថ្ងៃ |
| - ថ្ងៃទី ៣០-៣១ តុលា និង ០១ វិច្ឆិកា | - ព្រះរាជពិធីបុណ្យចំរើនព្រះជន្ម ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ | ឈប់ ០៣ ថ្ងៃ |
| - ថ្ងៃទី ០៩ វិច្ឆិកា | - ទិវាបុណ្យឯករាជ្យជាតិ | ឈប់ ០១ ថ្ងៃ |
| - ថ្ងៃទី ១៨-១៩-២០ វិច្ឆិកា | - ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក | ឈប់ ០៣ ថ្ងៃ |
| ថ្ងៃទី ១០ ធ្នូ | ទិវាសិទ្ធិមនុស្ស អន្តរជាតិ | ឈប់ ០១ ថ្ងៃ |

**មាត្រា ២ :** ពេលវេលាឈប់សម្រាកទាំងឡាយណា ដែលត្រូវចំថ្ងៃណាមួយ នៃថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ ( សៅរ៍ ឬ អាទិត្យ ) ត្រូវបានអោយឈប់ចំនួន ០១ ថ្ងៃ នៃថ្ងៃបន្ទាប់ជាបន្ថែមទៀត ។ ប៉ុន្តែក្នុងករណីត្រូវចំទាំងពីរថ្ងៃជាប់គ្នា គឺ ទាំងថ្ងៃ សៅរ៍ ទាំងថ្ងៃ អាទិត្យ នោះ ចំនួនថ្ងៃបន្ទាប់ដែលត្រូវបានអនុញ្ញាតអោយឈប់បន្ថែម ជាជំនួស គឺ ឈប់តែចំនួន ០១ ថ្ងៃប៉ុណ្ណោះ ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជា និរាករណ៍ ។

**មាត្រា ៤ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ខេត្ត ក្រុង ត្រូវអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ៧ ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ១០៥ អនក្រ.បក

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ ១០ ឆ្នាំ ២០០១

# អនុក្រឹត្យ

## ស្តីពីការបង្កើតវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ របស់ក្រសួងអប់រំ យុវជននិងកីឡា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ចុះថ្ងៃទី ២០ ខែ កក្កដា ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជននិងកីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជននិងកីឡា

-បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស

-បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ១៩៩១ ស្តីពីតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងពាណិជ្ជកម្ម

-តាមសំណើរបស់ក្រសួងអប់រំ យុវជននិងកីឡា

## សំរេច

**មាត្រា១:** ប្រែក្លាយ និង តំឡើងឋានៈ សាលាមធ្យមសិក្សាឯកទេសពាណិជ្ជកម្ម ទៅជាវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ National Institute of Business "វ.ជ.ព" ។

វិទ្យាស្ថាននេះត្រូវស្ថិតនៅក្រោមឱវាទ ក្រសួងអប់រំ យុវជននិងកីឡា ។

**មាត្រា២:** វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រមានភារៈកិច្ច :

-អប់រំបណ្តុះបណ្តាលធនធានមនុស្សតាំងពីកំរិតមធ្យមសិក្សាឯកទេស និង បរិញ្ញាប័ត្រ ដើម្បីឆ្លើយតប ទៅនឹងតំរូវការរីកចំរើននៃសេដ្ឋកិច្ចទីផ្សារសេរី និង គោលនយោបាយអាទិភាព សំរាប់ការអភិវឌ្ឍន៍ ប្រទេសជាតិរបស់រាជរដ្ឋាភិបាល ។

**មាត្រា៣:** វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រមានឋានៈស្មើថ្នាក់នាយកដ្ឋាន ។

**មាត្រា៤:** នាយកវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ មានបុព្វសិទ្ធិស្មើនឹងប្រធាននាយកដ្ឋាន និង មាននាយករងមួយរូប ឬ ច្រើនរូប ជាជំនួយការចាំបាច់ ។

**មាត្រា៥:** ចំពោះមុខនេះវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រមាន:

-ការិយាល័យរដ្ឋបាល និង ហិរញ្ញវត្ថុ

-ការិយាល័យសិក្សា

-ការិយាល័យទំនាក់ទំនងស្ថាប័ន-រោងចក្រ-សហគ្រាស

-ដេប៉ាតឺម៉ង់គណនេយ្យ

-ដេប៉ាតឺម៉ង់គ្រប់គ្រង

-ដេប៉ាតឺម៉ង់ម៉ាឃើតធីង

ទៅអនាគតវិទ្យាស្ថានជាតិនឹងអាចបើកការិយាល័យ និង ដេប៉ាតឺម៉ង់មួយចំនួនទៀតតាមសំណូមពរ ភារៈកិច្ចជាក់ស្តែង ។

**មាត្រា៦:** វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ កាន់កាប់ និងប្រើប្រាស់គណនេយ្យតាមប្រពន្ធ័គណនេយ្យសាធារណៈ ដែលត្រូវបានឧបត្ថម្ភពីថវិកាជាតិសំរាប់បណ្តុះបណ្តាល និងមានខ្ទង់គណនេយ្យដោយឡែក ។

**មាត្រា៧:** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា៨:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា រដ្ឋមន្ត្រីក្រសួង ផែនការ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួង ស្ថាប័នពាក់ព័ន្ធ និង វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ ត្រូវទទួលបន្ទុកអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហ៊ុន សែន

<u>ចម្លងជូន</u>

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៨ " ដើម្បីអនុវត្ត "

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...១០៩....អនក្រ.បក

រាជធានីភ្នំពេញ, ថ្ងៃទី ៧ ខែ តុលា ឆ្នាំ ២០០១

# អនុក្រឹត្យ

## ស្តីពីការតំឡើងឋានៈវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេសអោយមានឋានៈស្មើថ្នាក់នាយកដ្ឋាន

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ចុះថ្ងៃទី ២០ ខែ កក្កដា ១៩៩៤ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីការ រៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ខែ មិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំយុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និង គ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស

-បានឃើញសេចក្តីសំរេចលេខ ៨៩ សសរ ចុះថ្ងៃទី ២៩ / ធ្នូ/១៩៩៩ ស្តីពីការបង្កើតវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស

-តាមសំណើរបស់ក្រសួងអប់រំយុវជន និង កីឡា

### <u>**សំរេច**</u>

<u>**មាត្រា១:**</u> តំឡើងឋានៈវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេសអោយមានឋានៈស្មើថ្នាក់នាយកដ្ឋាននៃក្រសួងអប់រំយុវជន និង កីឡា ។

<u>**មាត្រា២:**</u> វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេសមានភារកិច្ច :

-រៀបចំអភិវឌ្ឍន៍កម្មវិធីសិក្សាតាមបែបការបណ្តុះបណ្តាលផ្អែកលើសមត្ថភាពសំរាប់ការប្រើប្រាស់ក្នុងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈទូទាំងប្រទេស ។

-បណ្តុះបណ្តាល និង វិក្រឹត្យការសាស្ត្រាចារ្យ គ្រូអប់រំ បណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ ។

៤៤

-បណ្តុះបណ្តាលការងារគ្រប់គ្រង គ្រឹះស្ថានអប់រំបច្ចេកទេស និង វិជ្ជាជីវៈដល់ជូនអ្នកគ្រប់គ្រង ។

-បណ្តុះបណ្តាលធនធានមនុស្សចាប់ពីកំរិត បឋមបច្ចេកទេសរហូតដល់ ឧត្តមសិក្សាបច្ចេកទេស តាមប្រពន្ធ័អប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ស្របតាមការអភិវឌ្ឍន៍របស់ប្រទេសជាតិ ។

-ធ្វើគំរោងផលិតសំភារៈឧបទេសសមស្របសំរាប់បណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ ។

-ស្រាវជ្រាវពីគោលការណ៍បណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈអន្តរជាតិ ពិសេសក្នុងតំបន់ ដើម្បីរួមចំណែកតំរង់ទិសដៅបណ្តុះបណ្តាលអោយសមស្របទៅតាមតំរូវការទីផ្សារពលកម្ម ។

-សិក្សាស្រាវជ្រាវបច្ចេកវិទ្យាថ្មីៗ រួមចំណែកអភិវឌ្ឍន៍សហគមន៍ ។

**មាត្រា៣:** នាយកវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស មានឋានៈស្មើនឹងប្រធាននាយកដ្ឋាន និង មាននាយករងមួយរូបឬច្រើនរូប ជាជំនួយការចាំបាច់ ។

**មាត្រា៤:** ចំពោះមុខវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស មាន :

-ការិយាលយ័រដ្ឋបាល និង ហិរញ្ញវត្ថុ

-ការិយាល័យ អភិវឌ្ឍន៍កម្មវិធីសិក្សា

-ការិយាល័យ អភិវឌ្ឍន៍នេនានសិក្សា

-ការិយាល័យ បច្ចេកទេស

-ដេប៉ាតឺម៉ង់ វិស្វកម្មសំណង់ស៊ីវិល

-ដេប៉ាតឺម៉ង់ វិស្វកម្ម អគ្គិសនី និង អេឡិចត្រូនិច

-ដេប៉ាតឺម៉ង់ វិទ្យាសាស្ត្រអប់រំ បណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ

ទៅអនាគត វិទ្យាស្ថាន ជាតិ នឹង អាចបើកការិយាល័យ និង ដេប៉ាតឺម៉ង់ជំនាញឯកទេស មួយចំនួនទៀត តាមសំណូមពរភារកិច្ចជាក់ស្តែង ។

**មាត្រា៥:** វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស កាន់កាប់ និង ប្រើប្រាស់ គណនេយ្យតាមប្រពន្ធ័គណនេយ្យសាធារណៈដែលត្រូវបានឧបត្ថមពីថវិកាជាតិសំរាប់បណ្តុះបណ្តាល និងមានខ្ទង់គណនេយ្យដោយឡែក ។

**មាត្រា៦:** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពី អនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា៧:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួងស្ថាប័ន័ពាក់ពន្ធ័ ត្រូវទទួលបន្ទុកអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

<u>ចំលងជូន</u>

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា៧ "ដើម្បីអនុវត្ត"

-ឯកសារ . កាលប្បវត្តិ

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ...១១០...អនក្រ.បក.

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០១

## អនុក្រឹត្យ

**ស្តីពីការតំឡើងឋានៈមជ្ឈមណ្ឌលបច្ចេកទេស និងវិជ្ជាជីវៈព្រះកុសុមៈ**
**ទៅជាវិទ្យាស្ថានពហុបច្ចេកទេស ព្រះកុសុមៈ**
**របស់ក្រសួងអប់រំ យុវជន និង កីឡា**

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ចុះថ្ងៃទី ២០ ខែ កក្កដា ១៩៩៤ ដែលប្រកាសអោយ ប្រើច្បាប់ ស្តីពីការ រៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ខែ មិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអប់រំយុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និង គ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស

-បានឃើញសេចក្តីសំរេចលេខ ៨១ សរច ចុះថ្ងៃទី ២១/៧/១៩៨១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការអនុញ្ញាតិអោយក្រសួងអប់រំ បង្កើត មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ

-តាមសំណើរបស់ក្រសួងអប់រំយុវជន និង កីឡា

## <u>សំរេច</u>

<u>មាត្រា១</u>: ប្រែក្លាយ និងតំឡើងឋានៈមជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈព្រះកុសុមៈ ទៅជាវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ Preah Kossomak Polytechnic Institute "វ.ព.ប.ព.ក." ។ វិទ្យាស្ថាននេះត្រូវស្ថិតនៅក្រោមឱវាទ ក្រសួងអប់រំ យុវជន និង កីឡា ។

<u>មាត្រា២</u>: វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈមានភារកិច្ច :

-អប់រំបណ្តុះបណ្តាលធនធានមនុស្សតាំងពីកំរិតបណ្តុះបណ្តាលវិជ្ជាជីវៈ មធ្យមសិក្សាបច្ចេកទេស និងវិស្វករ

ដើម្បីឆ្លើយតប ទៅនឹងតំរូវការរីកចំរើននៃសេដ្ឋកិច្ចទីផ្សារសេរី និង គោលនយោបាយអាទិភាព សំរាប់ការអភិវឌ្ឍន៍ ប្រទេសជាតិរបស់រាជរដ្ឋាភិបាល ។

**មាត្រា៣:** វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ មានឋានៈស្មើថ្នាក់នាយកដ្ឋាន ។

**មាត្រា៤:** នាយក វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ មានបុព្វសិទ្ធិស្មើនឹងប្រធាននាយកដ្ឋាន និងមាននាយករងមួយរូប ឬ ច្រើនរូប ជាជំនួយការចាំបាច់ ។

**មាត្រា៥:** ចំពោះមុខនេះ វិទ្យាស្ថាន ពហុបច្ចេកទេសព្រះកុសុមៈ មានៈ

-ការិយាលយ័រដ្ឋបាល និង ហិរញ្ញកិច្ច

-ការិយាល័យផែនការ និង អភិវឌ្ឍន៍

-ការិយាល័យ ទំនាក់ទំនងឧស្សាហកម្ម

-ការិយាល័យ អប់រំ

-ដេប៉ាតឺម៉ង់ សំណង់ស៊ីវិល

-ដេប៉ាតឺម៉ង់ អេឡិចត្រូនិច

-ដេប៉ាតឺម៉ង់ អគ្គិសនី

ទៅអនាគតវិទ្យាស្ថាន នឹងអាចបើកការិយាល័យ និងដេប៉ាតឺម៉ង់មួយចំនួនទៀតតាមសំណូមពរភារកិច្ចជាក់ស្តែង ។

**មាត្រា៦:** វិទ្យាស្ថាន ពហុបច្ចេកទេសព្រះកុសុមៈ កាន់កាប់ និងប្រើប្រាស់ គណនេយ្យតាមប្រព័ន្ធគណនេយ្យសាធារណៈ ដែលត្រូវកាន់ឧបត្ថម្ភពីថវិកាជាតិ សំរាប់បណ្តុះបណ្តាល និងមានខ្ទង់គណនេយ្យដោយឡែក ។

**មាត្រា៧:** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៨:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចំលងជូន

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា៨" ដើម្បីអនុវត្ត"

-ឯកសារ . កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៤៣៨ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពី សវនកម្មនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១១ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០០ ដែល ប្រកាសអោយប្រើច្បាប់ស្តីពី ច្បាប់បន្ថែមទៅលើច្បាប់ស្តីពី សវនកម្មនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០១/២៥៨ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការតែងតាំងអគ្គសវនករ អគ្គសវនកររង នៃអាជ្ញាធរសវនកម្មជាតិ

-យោងតាមសំណូមពរការងារចាំបាច់

## សំរេច

**មាត្រា ១** : ត្រូវបានតែងតាំងលោក **ចាំ ហៀង** ជាប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃអាជ្ញាធរសវនកម្មជាតិ ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន អគ្គសវនករនៃអាជ្ញាធរសវនកម្មជាតិ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០១*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>ចម្លងជូន</u> :

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*-ដូចមាត្រា ៣*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៣៩ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ ជាកិច្ចបច្ឆាមរណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៥០១ .១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា១:** ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជាកិច្ចបច្ឆាមរណៈ ជូនចំពោះសពវរសេនីយ៍ទោ **លាង សុច័ន្ទ** ជំនួយការប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន នៃក្រសួងមហាផ្ទៃ ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង-ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល :*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:...៤៤០...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តព្រៃវែង

### សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **សុខ្ឋ ស៊ីន** ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រៃវែង ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ដើម្បីរួមចំណែកអភិវឌ្ឍន៍ និង ស្តារហេដ្ឋារចនាសម្ព័ន្ធប្រទេសជាតិស្ថិតនៅក្នុងស្រុកបី គឺ ស្រុកកញ្ជៀច ស្រុកកំចាយមារ និង ស្រុកកំពង់លាវ ខេត្តព្រៃវែង សរុបទឹកប្រាក់ចំនួន ១៦១.២៩៧ USD ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/.

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៤១ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តព្រៃវែង

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនឯកឧត្តម **សៀង សាវ៉ាត់** និង លោកជំទាវ **ស៊ាន ឈុនហេង** អភិបាលរងទី៣ ក្រុងព្រះសីហនុ ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ដើម្បីរួមចំណែកអភិវឌ្ឍន៍ និង ស្តារហេដ្ឋារចនាសម្ព័ន្ធប្រទេសជាតិ ដូចជាកសាងព្រះវិហារ សាលារៀនសាលាបាលី ក្លោងទ្វារវត្ត និង ម៉ាស៊ីនភ្លើង ស្ថិតនៅក្នុងខេត្តព្រៃវែង សរុបទឹកប្រាក់ចំនួន ១៦៣.០៦៥ USD ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ៚

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៩៤៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ មេដាយមាសស្ថាបនាជាតិ ប្រគេនព្រះតេជគុណ ០២ព្រះអង្គ ដែលបានយកព្រះទ័យទុកដាក់ដឹកនាំ និង បរិច្ចាគនូវបច្ច័យ ដើម្បីកសាងសមិទ្ធផលនានាជាច្រើនក្នុងវិស័យព្រះពុទ្ធសាសនា ស្ថិតនៅក្នុងវត្តព្រែកសំរោង ស្រុកតាខ្មៅ ខេត្តកណ្តាល ដូចមានព្រះនាមខាងក្រោម ÷

១-ព្រះតេជគុណ **ឃឹម យឹម** ព្រះចៅអធិការវត្តព្រែកសំរោង បច្ច័យចំនួន ៩២.៥០០ USD និង ១១៣.៤០០.៥០០ រៀល

២-ព្រះតេជគុណ **សំរិទ្ធ សនសុជា** គ្រូសូត្រវត្តព្រែកសំរោង បច្ច័យចំនួន ១៦៩.២០០ USD និង ១៣.០០០.០០០ រៀល

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ១០ ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៤៤៣...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពត

## សំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ០៣ រូប ដែលបានចំណាយថវិកាជួយកសាងផ្លូវលំមួយខ្សែប្រវែង ១.៦៨៥ ម៉ែត្រ ជួសជុលទ្វារទឹកទំនប់អូរព្រាល ០២ កន្លែង ចាក់ដី និងជួសជុលខ្នងទំនប់ប្រវែង ១.០០០ ម៉ែត្រ កសាងរបងវត្តប្រវែង ៦៧៦ ម៉ែត្រ សង់ពីបេតុងអាមេ និងជួសជុលសាលារៀនបាន ០៣ បន្ទប់ ក្នុងវត្តបាលិលេយ្យក៍ ក្នុងឃុំច្រេះ ស្រុកជុំគីរី ខេត្តកំពត ចំណាយអស់ទឹកប្រាក់សរុប ៥៧.៨០០ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោមនេះ ÷

១- ឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម
២- ឯកឧត្តម **សោម ចិន** តំណាងរាស្ត្រមណ្ឌល ខេត្តកំពត
៣- លោក **ចៅ ភ្នុក** សប្បុរសជននៅសហរដ្ឋអាមេរិក

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ ១០ ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- កាលប្បវត្តិ-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ...៨៨៨...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ មេដាយមាសស្ថាបនាជាតិ ជូនសប្បុរសជន ០៣ រូប ដែលបានចំណាយថវិកាផ្ទាល់ខ្លួន ដើម្បីចូលរួមចំណែកក្នុងការកសាងសមិទ្ធផលនានាជាច្រើន ស្ថិតនៅក្នុងវត្តសុវណ្ណរាសីរតនារាម ឃុំសំរោង ស្រុកពញាឮ ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម ÷

| | | | |
|---|---|---|---|
| ១-អ្នកស្រី | អ៊ា | គីមសួ | ថវិកាចំនួន ១៧.១៨៥ ដុល្លារអាមេរិក |
| ២-លោកវររសេនិយឯក | ម៉ែន | ខណ្ឌម៉ូលី | ថវិកាចំនួន ១៤.៦០០ ដុល្លារអាមេរិក |
| ៣- អ្នកស្រី | លឹម | តា | ថវិកាចំនួន ១១.០០០ ដុល្លារអាមេរិក |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៤៤៥ អនក្រ - ពស

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ មេដាយមាសស្ថាបនាជាតិ ជូនសប្បុរសជន ០៤ រូប ដែលបានចំណាយថវិកាផ្ទាល់ខ្លួន ដើម្បីចូលរួមចំណែកក្នុងការកសាងសមិទ្ធផលនានាជាច្រើន ស្ថិតនៅក្នុងវត្តត្រ័យត្រឹង្ស ស្រុកពញាឮ ខេត្តកណ្តាល ដូចមានរាយព្រះនាមនិងនាមខាងក្រោម ÷

១-ព្រះគ្រូ ឈុំ ឡៅ (ឈានសុំយុត្តោ) ចៅអធិការវត្តត្រ័យត្រឹង្ស បច្ច័យចំនួន ១៨.២៧៥ ដុល្លារអាមេរិក
២-អ្នកឧកញ៉ា ទ្រី ហេង ថវិកាចំនួន ៥៥.០៥៧ ដុល្លារអាមេរិក
៣-លោកស្រី ប៊ុន សាមលេន ថវិកាចំនួន ២១.៨២៨ ដុល្លារអាមេរិក
៤-លោកមហាឧបាសិកា ប៊ុន សៀងលី (មាតាលោកជំទាវ ប៊ុន រ៉ានី ហ៊ុន សែន) ថវិកាចំនួន ១៥.៦៥០ ដុល្លារអាមេរិក

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ៩ ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- កាលប្បវត្តិ- ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៤៤៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

**ស ំ រ េ ច**

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក សា ថុលមយូរ៉ា ភ្នាក់ងារទេសចរណ៍អាប៉ិចរបស់ជប៉ុន ដែលបានជួយកសាងអាគារសិក្សា ០១ខ្នង មាន ០៥បន្ទប់ ធ្វើអំពីបេតុង ប្រក់ស៊ីហ្វ្រូ បំពាក់តុ- កៅអី សិស្ស- គ្រូ ក្តារខៀន អណ្តូងស្នប់ បង្គន់អនាម័យ ០១ខ្នង មាន ០២បន្ទប់ សរុបទឹកប្រាក់ចំនួន ២៦.០០០ ដុល្លារអាមេរិក ស្ថិតនៅក្នុងសាលាបឋមសិក្សាឈើទាល ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ៕

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ១០ ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៤.៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជន ០៦ រូប ដែលបានចំណាយនូវបច្ច័យ និង ថវិកា ដើម្បីកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា ស្ថិតនៅក្នុងស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដូចមានរាយព្រះនាម និង នាមខាងក្រោម ÷

**ក-មេដាយមាសស្ថាបនាជាតិ :**

ព្រះតេជគុណ **ពេញ សាម៉ន** ព្រះចៅអធិការវត្តក្រូចសើច បច្ច័យ ១១.៨៥០ USD

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-លោក | ឡេ | ខួន | អាជីវករផ្សារកំពង់កន្ទួត | ថវិកា ៥.៣២០ USD |
| ២-លោក, | ហ៊ុយ | នឹប | អាជីវករផ្សារកំពង់កន្ទួត | ថវិកា ៥.២៥៥ USD |
| ៣-លោក | អ៊ិន | នៅ | ប្រធានការិយាល័យធម្មការនិងសាសនាស្រុក | ថវិកា ៥.២៥០ USD |
| ៤-លោក | ជុំ | សែម | អាជីវករឃុំព្រែកកំពិស | ថវិកា ៥.២៣០ USD |
| ៥-លោក | ស្នួ | កែវ | មន្ត្រីហិរញ្ញវត្ថុសាលាស្រុកកណ្តាលស្ទឹង | ថវិកា ៥.១៨៥ USD |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។ល

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៤៤៨ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ

## សម្រេច

**មាត្រា ១ :** ត្រូវបានបំពាក់ ***មេដាយមាសស្ថាបនាជាតិ*** ជូនសមាគមភ្នំពេញអូរបែកកូម ( LION CLUBS ) បានស្វះស្វែងរកជំនួយដើម្បីសាងសង់អាគារសិក្សា ០១ ខ្នង មាន ៥ បន្ទប់ ស្ថិតនៅតំបន់អភិវឌ្ឍន៍ជនក្រីក្រភូមិទួលរកាកុះ សង្កាត់ព្រៃស ខ័ណ្ឌដង្កោ សរុបទឹកប្រាក់ចំនួន ៦០.០០០ ដុល្លារអាមេរិក។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះអោយ ទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ១០ ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៤៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តតាកែវ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជន ០៥ រូប ដែលបានចំណាយនូវបច្ច័យ និង ថវិកាផ្ទាល់ខ្លួន ដើម្បីកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា និង វិស័យអប់រំ ស្ថិតនៅក្នុងវត្តព្រៃផ្កាវ ឃុំនាម ស្រុកទ្រាំង ខេត្តតាកែវ ដូចមានរាយព្រះនាម និងនាមខាងក្រោម ÷

**ក-មេដាយមាសស្ថាបនាជាតិ :**

លោក ឌេត ធន ប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច និង ហិរញ្ញកិច្ច នៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ថវិកា ១៤.៥០០ USD និង ៦៤០.០០០ ៛

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

លោកគ្រូ ម៉ម សាម៉ន និង លោកស្រី នូ នួច សប្បុរសជននៅសហរដ្ឋអាមេរិក ថវិកា ៦.៥០០ USD

**គ-មេដាយសំរឹទ្ធស្ថាបនាជាតិ :**

១-ព្រះតេជគុណ មុំ ដោយ ចៅអធិការវត្តព្រៃផ្កាវ បច្ច័យ ៩០ USD និង ៧.២៥០.០០០៛

២-សពមហាឧបាសិកា ឌី ម៉ុក សប្បុរសជននៅរាជធានីភ្នំពេញ ថវិកា ១.១៦០ USD និង ៨.០០០.០០០ ៛

៣-លោក ម៉ុក ចំណាន មន្ត្រីពន្ធដាររាជធានីភ្នំពេញ ថវិកា ១.៦៩០ USD និង ១.០០០.០០០ ៛

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ១០ ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៤៥០ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ឆ្នាំង

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០១ គ្រឿង ជូនអង្គការ FIDR ដែលបានជួយកសាងអគារសិក្សា ០១ ខ្នង មាន ០៥ បន្ទប់ បំពាក់ដោយសំភារៈសិក្សាគ្រប់បន្ទប់ និង ជួយកសាងអគារទីចាត់ការនាយក ០១ ខ្នង មាន ០៣ បន្ទប់ធ្វើអំពីបេតុង បំពាក់គ្រឿងសង្ហារឹមមួយកំប្លេ នៅភូមិឈ្មូក ឃុំធ្លុកវៀន ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ចំណាយអស់ទឹកប្រាក់ចំនួន ២៧.០៣០ ដុល្លារអាមេរិក។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/៖

រាជធានីភ្នំពេញៈ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៤៩១ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយថ្នាក់ស្ថាបនាជាតិ** ជូនលោក HAN JAE GEN ប្រធានក្រុមហ៊ុន WEB TV WORLD WIDE Co.LTD នៃសាធារណរដ្ឋកូរ៉េ ដែលបាន ជួយឧបត្ថម្ភកុំព្យូទ័រ ចំនួន ១០ គ្រឿង ជួលគ្រូបង្រៀនបច្ចេកទេសប្រើប្រាស់ និង បំប៉នភាសាអង់គ្លេស និង កូរ៉េ រយៈពេល ០៣ ខែ ដល់នាយទាហាន ក្នុងទីចាត់ការអភិវឌ្ឍន៍ ព្រមទាំងបានចុះពិនិត្យព្យាបាលជម្ងឺដល់គ្រួសារយោធិន ដែលឈរជើងនៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ព្រះសីហនុរាជ ដោយចំណាយអស់ថវិកាសរុបចំនួន ៦.២៥០ ដុល្លារអាមេរិក ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ១៧ ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- កាលប្បវត្តិ- ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៥៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តតាកែវ

**ស ំ រេ ច**

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០១ គ្រឿង ប្រគេនព្រះតេជគុណ **ម៉ីខ ហ៊ិន** ពុទ្ធសុវណ្ណោ គង់នៅប្រទេសកាណាដា ដែលបានបរិច្ចាគបច្ច័យ ជួយកសាងបណ្ណាល័យ ០១ ខ្នង ជីកស្រះក្នុងវត្តថ្មីកជ្រៃ និង សមិទ្ធផលមួយចំនួនទៀត នៅក្នុងឃុំសំរោង ស្រុកត្រាំកក់ ខេត្តតាកែវ ចំណាយអស់បច្ច័យសរុបចំនួន ២២.៣១៣.១៩ ដុល្លារអាមេរិក ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ [illegible] ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៩២៣ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ចាម

### សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០១ គ្រឿង ជូនកញ្ញា **សំជិត ម៉ិនញ៉ារ៉ាសិរី** រស់នៅប្រទេសអូស្ត្រាលី ដែលបានជួយកសាង គុដិថ្ម ក្លោងទ្វារ នៅវត្តសូទិព្វ និង វត្តផ្តៅជុំ ជីកស្រះ អណ្តូងទឹកនិង បង្គន់អនាម័យ ព្រមទាំងជួយសង្គ្រោះប្រជាជន ដែលរងគ្រោះដោយទឹកជំនន់ នៅក្នុងស្រុកជើងព្រៃ ខេត្តកំពង់ចាម ចំណាយអស់ទឹកប្រាក់ចំនួន ៤៣ .៣០៥ ដុល្លារអាមេរិក ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/៖

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ១៧ ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាល

លេខ: ៤៥៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

***************

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១០២ អនក្រ.បក ចុះថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០០១ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុរបស់ក្រសួងបរិស្ថាន ទៅជាអគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សំ រេ ច

**មាត្រា ១** : តែងតាំងមន្ត្រីថ្នាក់អគ្គនាយករងចំនួន ០២រូប នៃក្រសួងបរិស្ថាន ដូចខាងក្រោម :

១- លោក អ៊ុ **ស៊ុនថាន់** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ទទួលបន្ទុកផ្ទាល់នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ

២- លោក នៅ **សំណាង** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ទទួលបន្ទុកផ្ទាល់នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធនិងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

ចម្លងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៥៥ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/ រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើ របស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១** : ត្រូវបានតែងតាំងលោក ជាក សារទី ជាទីប្រឹក្សាឯកឧត្តម យូ ហុកគ្រី ទេសរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងនាមសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០១
នាយករដ្ឋមន្ត្រី
ហ៊ុន សែន

**ចម្លងជូន** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៤៥៦ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសុវត្ថារា

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **ធិបឌិន្ទ** ជូនឯកឧត្តម **សុន គន្ធរ** ទីប្រឹក្សារាជរដ្ឋាភិបាល និងជាប្រធានអគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ ដែលមានស្នាដៃ និង គុណបំណាច់ឧត្តុង្គឧត្តម ក្នុងការបំពេញភារកិច្ច ស្វែងរកជំនួយផ្នែកហិរញ្ញវត្ថុ សំរាប់ការស្តារ និងអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសកម្ពុជា ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងនាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ១០ ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- កាលប្បវត្តិ - ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥៥៧ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /១១៩៨ /៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី រៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស /រកម/ ០១៩៦/ ១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### ស ំ រ េ ច

**មាត្រា ១** : ត្រូវបានតែងតាំង:

១- លោក **ជួង សុផល** ជាព្រឹទ្ធសាស្ត្រាចារ្យ នៃមហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម

២- លោក **ឈុំ គឹតលង់** ជាព្រឹទ្ធសាស្ត្រាចារ្យ នៃមហាវិទ្យាល័យផលិកម្ម និងបសុព្យាបាល

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ តុលា ឆ្នាំ ២០០១*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣ "ដើម្បីអនុវត្ត"*
- *កាលប្បវត្តិ-ឯកសារ*

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៨៥៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

## សំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ប្រគេន និង ជូនសប្បុរសជន ១៤ រូប ដែលបានបរិច្ចាគនូវបច្ច័យ និង ថវិកាផ្ទាល់ខ្លួន ដើម្បីជួយកសាងឧបដ្ឋានសាលា ហោត្រ័យ ក្លោងទ្វារវត្ត ស្រះទឹក ស្ថិតនៅក្នុងវត្តតាភេម ឃុំកំបូល ស្រុកអង្គស្នួល ខេត្តកណ្តាល ដូចមានរាយព្រះនាម និងនាមខាងក្រោមនេះ ÷

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-អ្នកស្រី | ធូច | អូន | | ថវិកា ១១.៥០០ USD |
| ២-លោកស្រី | ឌុច | ប៊ិច | នៅសហរដ្ឋ | ថវិកា ១០.០០០ USD |
| ៣-លោក | នូ | សឿន | អាចារ្យវត្ត | ថវិកា ១០.០០០ USD |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-ព្រះតេជគុណធម្មថេរោ | ហ៊ឹម | ប៊ុនធឿន | ចៅអធិការវត្ត | បច្ច័យ ៥.០០០ USD |
| ២-ព្រះតេជគុណ | ប៊ូ | មាស | | បច្ច័យ ៥.០០០ USD |
| ៣-ព្រះតេជគុណ | ខិន | សុទ្ធ | | បច្ច័យ ៥.០០០ USD |
| ៤-លោកយាយ | លើក | មិត | | ថវិកា ៩.០០០ USD និង ៣.០០០.០០០ រៀល |

គ-មេដាយសិរីវឌ្ឍស្ថាបនាជាតិ :

| | | | | |
|---|---|---|---|---|
| ១-លោក | ឃឹម សារឿន | អាចារ្យវត្ត | ថវិកា | ២.០០០ USD |
| ២-លោក | កុយ ភួង | គណៈកម្មការវត្ត | ថវិកា | ២.០០០ USD |
| ៣-លោក | ឌុច សំអុល | គណៈកម្មការវត្ត | ថវិកា | ២.០០០ USD |
| ៤-លោក | ភួន ភាន | គណៈកម្មការវត្ត | ថវិកា | ២.០០០ USD |
| ៥-លោក | ឡឹង ថន | គណៈកម្មការវត្ត | ថវិកា | ២.០០០ USD |
| ៦-លោកយាយ | ខឹម មម | | ថវិកា | ២.០០០ USD |
| ៧-លោក | កង យ៉ុន | គណៈកម្មការវត្ត | ថវិកា | ២.០០០ USD |

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែតុលា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៤៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការអនុវត្តន៍វិន័យមន្ត្រីនគរបាលជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការ បង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានអនុវត្តវិន័យចំពោះលោកវរសេនីយ៍ឯក សុខ សុភ័ក្រ្ត អត្តលេខ ០៣៧៣ មន្ត្រីនគរបាលជាតិ នៃក្រសួងមហាផ្ទៃ ក្នុងរូបភាពដកហូតឋានន្តរសក្តិ និងបណ្តេញចេញផុតពីក្របខ័ណ្ឌនគរបាលជាតិ ដោយមូលហេតុជាប់ពាក់ព័ន្ធការជួញដូរគ្រឿងញៀនខុសច្បាប់ ។

**មាត្រា ២ :** ប្រាក់បៀវត្ស- របបឧបត្ថម្ភផ្សេងៗត្រូវកាត់ចេញពីក្របខ័ណ្ឌនគរបាលជាតិ នៃក្រសួងមហាផ្ទៃ ចាប់តាំងពីខែ វិច្ឆិកា ឆ្នាំ ២០០១ នេះតទៅ ។

**មាត្រា ៣ :** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៧០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តសៀមរាប

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ឈៅ ឆួក** ប្រធាននាយកដ្ឋានជលផល នៃក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចំនួន ២២.៧៥៣ USDជួយកសាងអគារសិក្សា ០១ ខ្នង មានបីបន្ទប់ នៅសាលាបឋមសិក្សា ហ៊ុន សែន គ្រួស ភូមិសាលាកន្សែង ឃុំស្វាយដង្គុំ ស្រុកសៀមរាប ខេត្តសៀមរាប ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ . ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ - ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៦១ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /១១៩៨ /៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ /នស /៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស /រកម /០១៩៦ /០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងសុខាភិបាល
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានតែងតាំង លោកស្រីឱសថ. **ឆា គឹមឆាយ** ជាប្រធាននាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខាពេទ្យ និង គ្រឿងសំអាង នៃក្រសួងសុខាភិបាល ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមាននាមចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០១*

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៦២ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស . ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៥៤ . អនក្រ . បក / ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៧២ / អនក្រ . បក / ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតក្រុមហ៊ុន ហ្រ្គីនត្រេដ
- យោងតាមសំណើររបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សំរេច

**មាត្រា ១** : ត្រូវបានតែងតាំងលោក ទេស វ៉េងដា បច្ចុប្បន្នអគ្គនាយកក្រុមហ៊ុនហ្រ្គីនត្រេដ អោយនៅបន្តអាណត្តិ ជាអគ្គនាយកក្រុមហ៊ុនហ្រ្គីនត្រេដ នៃក្រសួងពាណិជ្ជកម្ម ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០១*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ- កាលប្បវត្តិ*

III,C,Chp,40

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៥ .សសរ

## សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការ

## ដើម្បីអភិវឌ្ឍចលនាភូមិមួយ ផលិតផលមួយ និងត្រៀមរៀបចំ

## សន្និសីទអាស៊ី-ក្យូស៊ូ ស្តីពីចលនាភូមិមួយ ផលិតផលមួយ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-តាមតំរូវការចាំបាច់របស់រាជរដ្ឋាភិបាល និង តាមសំណើរបស់ខេត្តអយតា ប្រទេសជប៉ុន

**ប្រការ១ :** បង្កើតគណៈកម្មការដើម្បីត្រៀមរៀបចំ សន្និសីទនិងកិច្ចប្រជុំកំពូលអាស៊ី-ក្យូស៊ូ និង សិក្ខាសាលាស្តីពីចលនាភូមិមួយ ផលិតផលមួយ ដែលមានសមាសភាពដូចតទៅ:

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **សុខ អាន** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២. ឯកឧត្តម | **វ៉ា ហួត** | ប្រធាន OBSESS | អនុប្រធាន |
| ៣. ឯកឧត្តម | **សុខ ចិន្តា** | អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៤. លោក | **ណាកាណេ កេអ៊ីជី** | តំណាងអង្គការ JETRO ប្រចាំនៅកម្ពុជា | ទីប្រឹក្សា |
| ៥. ឯកឧត្តម | **ត្រាក់ ថៃសៀង** | អភិបាលរងក្រុងភ្នំពេញ | សមាជិក |
| ៦. ឯកឧត្តម | **ចាប ញ៉ាលីវុធ** | អភិបាលខេត្តសៀមរាប | សមាជិក |
| ៧. ឯកឧត្តម | **សយ សុខា** | អគ្គលេខាធិការ OBSESS | សមាជិក |
| ៨. បណ្ឌិត | **ជា វ៉ាន់ដេត** | អនុប្រធាននាយកដ្ឋាន ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

៩. ឧកញ៉ា **ម៉ុង ឫទ្ធី** ប្រធានក្រុមហ៊ុន ម៉ុង ឫទ្ធី គ្រុប សមាជិក

១០. ឧកញ៉ា **អ៊ុំ ម៉ិនហួទ** ប្រធានក្រុមហ៊ុន AZ Distribution សមាជិក

**ប្រការ២ :** គណៈកម្មការនេះមានភារកិច្ចពិចារណានូវលទ្ធភាព នៃការអភិវឌ្ឍចលនាភូមិមួយ ផលិតផលមួយ និងរៀបចំសន្និសីទអាស៊ី-ក្បូស៊ូ ស្តីពីចលនាភូមិមួយ ផលិតផលមួយ នាឆ្នាំ ២០០២ នៅភ្នំពេញ។

**ប្រការ៣ :** គណៈកម្មការនេះនឹងសហការជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ខេត្ត-ក្រុង សហគ្រាស ព្រមទាំងតំណាងខេត្តអយតា ដើម្បីអភិវឌ្ឍចលនាភូមិមួយ ផលិតផលមួយ និងរៀបចំសន្និសីទអាស៊ី-ក្បូស៊ូ ស្តីពីចលនាភូមិមួយ ផលិតផលមួយ អោយបានជោគជ័យ។

**ប្រការ៤ :** ដើម្បីរៀបចំការងារនេះអោយបានល្អនិងរលូន សមាជិកនៃគណៈកម្មការនេះ ត្រូវចូលរួមរាល់កិច្ចប្រជុំក្នុងក្រុមការងារនៃតំណាងប្រទេសនិងតំបន់ ដែលគ្រោងចូលរួមសន្និសីទអាស៊ី-ក្បូស៊ូ ស្តីពីចលនាភូមិមួយ ផលិតផលមួយ ពេលកាលបរិច្ឆេទ។

**ប្រការ៥ :** គណៈកម្មការនេះនឹងបង្កើតលេខាធិការដ្ឋានមួយនៅទីស្តីការគណៈរដ្ឋមន្ត្រី ដែលដឹកនាំដោយ បណ្ឌិត **ឌូ ទាវ៉ន់ដេត** ដើម្បីរៀបចំនិងទទួលនូវរាល់ឯកសារពាក់ព័ន្ធនឹងសន្និសីទនេះ។

**ប្រការ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត-ក្រុង ប្រធានសហគ្រាស ព្រមទាំងសាមីខ្លួនដែលមានរាយនាមក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ៨៧ ខែ តុលា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ដូចប្រការ៦
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
No. ៧៩៤ MoC / M 2001

ភ្នំពេញ,ថ្ងៃទី១៨ខែ តុលា ឆ្នាំ ២០០១

# ប្រកាស

## ស្តីពីលទ្ធផល នៃ ការដេញថ្លៃកូតាសំរាប់នាំចេញ សំលៀកបំពាក់ទៅកាន់សហរដ្ឋអាមេរិក ក្នុងឆ្នាំ ២០០១

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញរាជក្រមលេខ នស / រកម / ០១៩៦ / ១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ-បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃក្រសួងពាណិជ្ជកម្ម ។
- យោងតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញវាយនភ័ណ្ឌ និង ផលិតផលវាយនភ័ណ្ឌធ្វើពីកប្បាស ឡែន សរសៃសិប្បនិម្មិតធ្វើពីដៃមនុស្ស សរសៃរុក្ខជាតិគ្មានជាតិកប្បាស និង សរសៃល្បាយសូត្រ រវាងរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលសហរដ្ឋអាមេរិក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៩ ។
- យោងតាមកិច្ចប្រជុំគណៈរដ្ឋមន្ត្រីនាថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៩៩ ។
- យោងតាមប្រកាសក្រសួងពាណិជ្ជកម្មលេខ ២៦៧ MoC/M2001 ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០១ ស្តីពីការដាក់អោយដេញថ្លៃ លើកូតាសំលៀកបំពាក់ដែលត្រូវនាំចេញទៅកាន់សហរដ្ឋអាមេរិក ក្នុងឆ្នាំ ២០០១ ។
- យោងតាមការចាំបាច់នៃការងារ ។

## សំរេច

**ប្រការ ១** : ទទួលស្គាល់លទ្ធផលនៃការដេញថ្លៃកូតា តាមប្រភេទសំលៀកបំពាក់នីមួយ ៗ សំរាប់ការនាំចេញទៅកាន់សហរដ្ឋអាមេរិកក្នុងឆ្នាំ ២០០១ ដែលបានប្រព្រឹត្តទៅនាថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០១ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ A ។

Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister' s Mobile Phone (855-12) 821888 Facsimile: (855-23) 213288

**ប្រការ ២ :** ក្រុមហ៊ុនទាំងឡាយដែលមានចែងក្នុងឧបសម្ព័ន្ធ A នៃប្រការ ១ ត្រូវបង់ប្រាក់បន្ថែម ៩០% អោយបានមុនថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០១ ។ ការខកខានបង់ នឹងអាចនាំអោយមានការរឹបអូសប្រាក់កក់ ១០% និងការបង្វិលកូតាដែលដេញបានយកទៅទុកដេញថ្លៃ នៅលើកក្រោយវិញ ។ ក្រសួងពាណិជ្ជកម្មរក្សាសិទ្ធិក្នុងការមិនអនុញ្ញាតអោយក្រុមហ៊ុននោះចូលរួមក្នុងការដេញថ្លៃកូតាលើកក្រោយៗទៀត ។

**ប្រការ ៣ :** នាយកខុទ្ទកាល័យ អគ្គនាយកបច្ចេកទេស ប្រធាននាយកដ្ឋានកាំកុងត្រូល ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ប្រធាននាយកដ្ឋានរដ្ឋបាល រាល់ផលិតករសំលៀកបំពាក់ និង សមាជិកគណៈកម្មការគ្រប់គ្រងកូតាសំរាប់នាំចេញ ត្រូវទទួលអនុវត្តនូវប្រកាសនេះ អោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម ប្រសិទ្ធ

**ចំលងជូន :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច ការងារ-បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា

" ដើម្បីជ្រាបជាពត៌មាន"

- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ANNEX - A** ក្រសួង ពាណិជ្ជកម្ម - MINISTRY OF COMMERCE 9:55 AM, 10/18/01

**MINISTRY OF COMMERCE**
TENDER of QUOTA

# TENDER of QUOTA
## October 18,2001

| ID | COMPANY NAME | 340/640 QUANTITY OF TENDER | | | | |
|---|---|---|---|---|---|---|
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 173,924 | $0.25 | | | |
| 1 | MSI Garment Cambodia Ltd | 7,500 | $0.35 | $2,625.00 | $262.50 | $2,362.50 |
| 2 | Luen Thai Garment Cambodia Co Ltd | 36,800 | $0.25 | $9,200.00 | $920.00 | $8,280.00 |
| 3 | C-One Cambodia Garment Co Ltd | 8,000 | $0.25 | $2,000.00 | $200.00 | $1,800.00 |
| | TOTAL | 52,300 | | $13,825.00 | $1,382.50 | $12,442.50 |

| ID | COMPANY NAME | 345 QUANTITY OF TENDER | | | | |
|---|---|---|---|---|---|---|
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 2,955 | $1.00 | | | |
| 1 | Universal Apparel Cambodia Co Ltd | 80 | $2.50 | $200.00 | $20.00 | $180.00 |
| 2 | Flying Dragon Cambodia Garment Co Ltd | 1,400 | $1.00 | $1,400.00 | $140.00 | $1,260.00 |
| | TOTAL | 1,480 | | $1,600.00 | $160.00 | $1,440.00 |

| ID | COMPANY NAME | 347/34/647/648 QUANTITY OF TENDER | | | | |
|---|---|---|---|---|---|---|
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 122,444 | $1.00 | | | |
| 1 | PDC Garment Ltd | 7,200 | $1.60 | $11,520.00 | $1,152.00 | $10,368.00 |
| 2 | Suntex PTE,. Ltd | 1,000 | $1.10 | $1,100.00 | $110.00 | $990.00 |
| 3 | In Fong Cambodia Garment Co Ltd | 1,230 | $1.10 | $1,353.00 | $135.30 | $1,217.70 |
| 4 | Flying Dragon Cambodia Garment Co Ltd | 6,300 | $1.00 | $6,300.00 | $630.00 | $5,670.00 |
| 5 | Grace Sun Cambodia Garment Co Ltd | 17,000 | $1.00 | $17,000.00 | $1,700.00 | $15,300.00 |
| | TOTAL | 32,730 | | $37,273.00 | $3,727.30 | $33,545.70 |

| ID | COMPANY NAME | 352/652 QUANTITY OF TENDER | | | | |
|---|---|---|---|---|---|---|
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 57,482 | $0.20 | | | |
| 1 | Wilson Garment Cambodia Co ,. Ltd | 30,000 | $0.36 | $10,800.00 | $1,080.00 | $9,720.00 |
| 2 | Shingtex Cambodia Co Ltd | 832 | $0.30 | $249.60 | $24.96 | $224.64 |
| 3 | In Fong Cambodia Garment Co Ltd | 2,150 | $0.30 | $645.00 | $64.50 | $580.50 |
| 4 | Sharp Casual Co Ltd | 18,360 | $0.30 | $5,508.00 | $550.80 | $4,957.20 |
| 5 | Eternal Way Cambodia Garment Ltd | 6,140 | $0.20 | $1,228.00 | $122.80 | $1,105.20 |
| | TOTAL | 57,482 | | $18,430.60 | $1,843.06 | $16,587.54 |

| ID | COMPANY NAME | 438 QUANTITY OF TENDER | | | | |
|---|---|---|---|---|---|---|
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 34,774 | $0.50 | | | |
| 1 | Park Shun Knitting Factoring Co Ltd | 1,150 | $0.50 | $575.00 | $57.50 | $517.50 |
| | TOTAL | 1,150 | | $575.00 | $57.50 | $517.50 |

**ANNEX - A**

ក្រសួង ពាណិជ្ជកម្ម - MINISTRY OF COMMERCE

9:55 AM, 10/18/01

| ID | COMPANY NAME | 638/639 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 149,298 | $0.25 | | | |
| 1 | Yung Wah Industrial ( Cambodia ) Co Ltd | 3,000 | $0.35 | $1,050.00 | $105.00 | $945.00 |
| 2 | Quality Textiles Co Ltd | 7,000 | $0.35 | $2,450.00 | $245.00 | $2,205.00 |
| 3 | YGM Cambodia Ltd | 2,260 | $0.35 | $791.00 | $79.10 | $711.90 |
| 4 | Jacqsintex Industries Cambodia Co Ltd | 8,800 | $0.25 | $2,200.00 | $220.00 | $1,980.00 |
| | **TOTAL** | **21,060** | | **$6,491.00** | **$649.10** | **$5,841.90** |

| ID | COMPANY NAME | 645/646 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 25,160 | $0.25 | | | |
| 1 | Terratex Knitting Garment ( Int'l ) Fty Ltd | 5,600 | $0.45 | $2,520.00 | $252.00 | $2,268.00 |
| 2 | Fortune Garment & Woolen Knitting Factory Co Ltd | 920 | $0.25 | $230.00 | $23.00 | $207.00 |
| | TOTAL | **6,520** | | **$2,750.00** | **$275.00** | **$2,475.00** |

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ: 438 សសរ.កសក

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើតគណៈកម្មការកំណត់ដីភូមិនិងដីកសិកម្ម ដែលប្រជាពលរដ្ឋកំពុងធ្វើអាជីវកម្មក្នុងដែនព្រៃសម្បទាន

~~~~~~~~

## រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
  បានឃើញព្រះរាជក្រឹត្យលេខ នស ./រកត./ ១១៩៨./ ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សំរេច

**ប្រការ១** : បង្កើតគណៈកម្មការមួយ ដែលមាន សមាសភាពដូចខាងក្រោម :

១-ឯកឧត្តម អ៊ុក សុខុន អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសទ ជាប្រធាន

២- លោក ជា សំអាង អនុប្រធាននាយកដ្ឋានរុក្ខា-ប្រមាញ់ អនុប្រធាន

៣- លោក ចាយ សាគុណ អនុប្រធាននាយកដ្ឋានផែនការ-ស្ថិតិនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៤- លោក ឆេង គីមស៊ុន ប្រធានការិយាល័យកិច្ចការព្រៃឈើ (នរប្រ) សមាជិក

៥- លោក ចាន់ សុផល អនុប្រធានវិទ្យាស្ថានសិក្សាស្រាវជ្រាវព្រៃឈើនិងសត្វព្រៃ (នរប្រ) សមាជិក

៦- លោក បាង្សជូន ចំរ៉ុង អនុប្រធានការិយាល័យផែនការ ( ន.ផ.ស ) សមាជិក

៧- លោក មាស មករា មន្ត្រីនាយកដ្ឋាន រុក្ខា-ប្រមាញ់ សមាជិក

**ប្រការ២** : គណៈកម្មការនេះ មានភារៈកិច្ច :

១-ធ្វើការសិក្សាស្រាវជ្រាវដីភូមិនិងដីកសិកម្មដែលប្រជាពលរដ្ឋកំពុងធ្វើអាជីវកម្ម នៅគ្រប់ព្រៃសម្បទានទាំងអស់ ដោយសហការជាមួយមន្ទីរកសិកម្មរុក្ខាប្រមាញ់និងនេសាទខេត្ត-ក្រុងសាមី ។
~~~~~~~~

២-ចុះវាស់វែងកំណត់ដីភូមិ និងដីកសិកម្មដែលប្រជាពលរដ្ឋកំពុងធ្វើអាជីវកម្ម នៅក្នុងដែនព្រៃសម្បទាន ។

៣-រៀបចំសេចក្ដីព្រាងអនុក្រឹត្យ ស្ដីពីការកាត់ផ្ទៃដីភូមិ និង ដីកសិកម្មដែលប្រជាពលរដ្ឋកំពុងធ្វើអាជីវកម្មចេញពីព្រៃសម្បទានជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**ប្រការ៣** : អគ្គនាយក អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានផែនការ-ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានរុក្ខា-ប្រមាញ់ ប្រធានមន្ទីរកសិកម្មរុក្ខាប្រមាញ់និងនេសាទគ្រប់ខេត្ត-ក្រុង និងឯកឧត្ដម អស់លោក ដែលមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តសេចក្ដីសំរេចនេះអោយមាន ប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញៈ ថ្ងៃទី 18 ខែ 10 ឆ្នាំ ២០០១

រដ្ឋមន្ត្រី

**កន្លែងទទួលៈ**

-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់
-គ្រប់សាលាខេត្ត-ក្រុងពាក់ព័ន្ធ
"ដើម្បីជូនជ្រាប"
-ដូចប្រការ៣
"ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion king**

**ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល**
**Ministry of Industry,Mines and Energy**
№ ៧៨២ ឧរមក.ប្រក

រាជធានីភ្នំពេញ. ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០១

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណា ព្រះបាទសម្តេចនរោត្តមសីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ន.ស / រកម / ០១៩៦ / ០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ. បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញលិខិតលេខ ១៧៣៥/០១ គ.វ.ក ចុះថ្ងៃទី ០៦.០៦.២០០១ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។
- បានឃើញប្រកាសលេខ ២០៤ ប.ស្ថ.ប្រ.ក វហបស្ថ ចុះថ្ងៃទី ២៨.០៩.២០០១ របស់ក្រសួងបរិស្ថាន ។
- បានឃើញលិខិតលេខ ១៤៣ ល អ ចុះថ្ងៃទី ១៩.០២. ២០០១ របស់សាលាខេត្តកណ្តាល ។
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ក្បាលកោះ ហ្គាមេន ខូ អិលធីឌី ចុះថ្ងៃទី ២៧.០៩.២០០១ ។

## សម្រេច

<u>ប្រការ១</u>: អនុញ្ញាតឱ្យក្រុមហ៊ុន ក្បាលកោះ ហ្គាមេន ខូ អិលធីឌី ( KBAL KOAH GARMENT CO.,LTD ) តំណាងដោយលោក LIN CHIN YI សញ្ជាតិ ចិន( តៃវ៉ាន់) អាយុ ៤០ ឆ្នាំ ភេទប្រុស កាន់លិខិតឆ្លងដែនលេខ M15122127 ចុះថ្ងៃទី 30.04.98 បង្កើតរោងចក្រ "កាត់ដេរសំលៀកបំពាក់" ដែលមានឈ្មោះថា "ក្បាលកោះ ហ្គាមេន" មានទីតាំងស្ថិតនៅ ភូមិជ្រោយអំពិល ឃុំក្បាលកោះ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

ប្រការ២ : ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម-រ៉ែ និង ថាមពល ឱ្យបានសំរេច ក្នុងរយៈពេល១២ខែ ដោយរាប់បញ្ចូលទាំងរយៈពេលសាកល្បងផង ។

ប្រការ៣ : រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសំលៀកបំពាក់ "ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤ : ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥ : ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦ : រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវសុំវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្ម ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៧: ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ស្តីពីការងារ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងច្បាប់បទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្មរបស់ក្រុមហ៊ុន ។

ប្រការ៨ : ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរ នឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវអស់សុពលភាព ។

ប្រការ៩ : អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកណ្តាល និង ប្រធានក្រុមហ៊ុន ក្បាលកោះ ហ្គាមេន ខូ អិលធីឌី ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន ។

ប្រការ១០ : ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ចម្លងជូន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច-ការងារ-បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាខេត្តកណ្តាល

"ដើម្បីជូនជ្រាបជាពត៌មាន"
- ដូចប្រការ ៩ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

សុយ សែម

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion king**

**ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល**
**Ministry of Industry,Mines and Energy**
№ ៧៨៣ ឧករថ - ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០១

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណា ព្រះបាទសម្តេចនរោត្តមសីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ន.ស / រកម / ០១៩៦ / ០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ. បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការ រៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញលិខិតលេខ ១១៩៥/០១ គ.វ.ក ចុះថ្ងៃទី ២០.០៤.២០០១ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។
- បានឃើញប្រកាសលេខ ១៣១ ប.ស្ត.ប្រ.ក វហបស្ត ចុះថ្ងៃទី ០៦ .០៦.២០០១ របស់ក្រសួងបរិស្ថាន ។
- បានឃើញលិខិតលេខ ៤១៥ លអ.ស ចុះថ្ងៃទី ០៧.០៨.២០០១ របស់សាលាក្រុងភ្នំពេញ ។
- យោងពាក្យស្នើរបស់ក្រុមហ៊ុន យៀល ខេមបូឌា ម៉ូធ័រ (វ៉ាយ ស៊ី អិម) ចុះថ្ងៃទី០២.០៨.២០០១។

## សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន យៀល ខេមបូឌា ម៉ូធ័រ (វ៉ាយ ស៊ី អិម) ( YIELD CAMBODIA MOTOR Co., LTD. (YCM) ) តំណាងដោយលោក សាំង រចនា អាយុ ៦៣ឆ្នាំ ភេទប្រុស សញ្ជាតិ ខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ០៦១១៦៤៣កព ចុះថ្ងៃទី១៥.០២.៨៩ បង្កើតរោងចក្រ "**ផ្គុំគម្លើងម៉ូតូ** " ដែលមានឈ្មោះថា" យៀល ខេមបូឌា ម៉ូធ័រ (វ៉ាយ ស៊ី អិម) មានទីតាំងស្ថិតនៅដីឡូត៍លេខ៣១ ផ្លូវលេខ៥៩៨និង៣៣៩ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

ប្រការ២ : ក្រុមហ៊ុនត្រូវរៀបចំរោងចក្រឡើងតាមប្លង់ ដែលបានតកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ឱ្យបានសំរេចក្នុងរយៈពេល ១២ ខែ ដោយរាប់បញ្ចូលទាំងរយៈពេលសាកល្បងផង ។

ប្រការ៣ : រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ " ផ្គុំតម្លើងម៉ូតូ YAMAHA " ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤ : ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥ : ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦ : រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវស៊ើវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្ម ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៧: ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ស្តីពីការងារ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងច្បាប់បទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្មរបស់ក្រុមហ៊ុន ។

ប្រការ៨ : ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ល្មើសធ្ងន់ធ្ងរ នឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវអស់សុពលភាព ។

ប្រការ៩ : អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និង ប្រធានក្រុមហ៊ុន យៀល ខេមបូឌា ម៉ូធ័រ ( វ៉ាយ ស៊ី អិម) ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន ។

ប្រការ១០ : ប្រកាសនេះមានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ចម្លងជូន
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងសង្គមកិច្ច-ការងារ-បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
" ដើម្បីជូនជ្រាបជាពត៌មាន "
-ដូចប្រការ ៩ " ដើម្បីអនុវត្ត "
-ឯកសារ-កាលប្បវត្តិ

ស៊ុយ សែម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion king

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry,Mines and Energy
N° [illegible]

រាជធានី-ភ្នំពេញ,ថ្ងៃទី..១៥..ខែ..តុលា..ឆ្នាំ២០០១

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។

- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណា ព្រះបាទសម្តេចនរោត្តមសីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ន.ស / រកម / ០១៩៦ / ០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ. បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញលិខិតលេខ ២២០៨/០១ គ.វ.ក ចុះថ្ងៃទី ១៩.០៧.២០០១ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។
- បានឃើញប្រកាសលេខ ១៨៩ ប.ស្ក.ប្រ.ក វហបស្ក ចុះថ្ងៃទី ២០.០៨.២០០១ របស់ក្រសួងបរិស្ថាន ។
- បានឃើញលិខិតលេខ ២៨២៨ លអ.ស ចុះថ្ងៃទី ២៥.០៩.៩៨ របស់សាលាក្រុងភ្នំពេញ ។
- យោងពាក្យស្នើរបស់ក្រុមហ៊ុន កាង នីង ខូ អិលធីឌី ចុះថ្ងៃទី១៩.០៨.២០០១។

## សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន កាង នីង ខូ អិលធីឌី (KANG NING Co.,LTD.) តំណាងដោយលោក KAO KANG-NING សញ្ជាតិចិន ( តៃវ៉ាន់) អាយុ២៦ ឆ្នាំ ភេទប្រុស កាន់លិខិតឆ្លងដែនលេខ M13626480 ចុះថ្ងៃទី 25.03.97 បង្កើតរោងចក្រ "ផលិតប្រដាប់ព្យួរសំលៀកបំពាក់" ដែលមានឈ្មោះថា "កាង នីង" មានទីតាំងស្ថិតនៅផ្លូវលេខ ១៥ ភូមិទូលសង្កែ សង្កាត់ទូលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ២ : ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ឱ្យបានសំរេច ក្នុងរយៈពេល ០៦ខែ ដោយរាប់បញ្ចូលទាំងរយៈពេលសាកល្បងផង ។

ប្រការ៣ : រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ " ផលិតប្រដាប់ព្យួរសំលៀកបំពាក់ " ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤ : ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥ : ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦ : រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវសុំវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្ម ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៧ : ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ស្តីពីការងារ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន នឹងការគ្រប់គ្រងធនធានធម្មជាតិ និងច្បាប់បទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្មរបស់ក្រុមហ៊ុន ។

ប្រការ៨ : ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរ នឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវអស់សុពលភាព ។

ប្រការ៩ : អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និង ប្រធានក្រុមហ៊ុន កាង នីង ខូ អិលធីឌី ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀង១ខ្លួន ។

ប្រការ១០ : ប្រកាសនេះមានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ចម្លងជូន
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងសង្គមកិច្ច-ការងារ-បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
" ដើម្បីជូនជ្រាបជាពត៌មាន "
-ដូចប្រការ ៩ " ដើម្បីអនុវត្ត "
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងផែនការ

លេខ : ... ផ.ក ប្រ.ក

រាជធានីភ្នំពេញ ថ្ងៃទី ... ខែតុលា ឆ្នាំ២០០១

# ប្រកាស

## ស្តីពី

## ការបង្កើតក្រុមការងារនៃអនុគណៈកម្មការ ផែនការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច

## រដ្ឋមន្ត្រីក្រសួងផែនការ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៦៩ ចុះថ្ងៃទី៣០ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញសេចក្តីសំរេចលេខ ០១៤ /០១ សរ /ឃ.គ.ស ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០១ ស្តីពីការបង្កើតអនុគណៈកម្មការនានាចំណុះគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងផែនការ

## សំរេច

**ប្រការ១ :** បង្កើតក្រុមការងារនៃអនុគណៈកម្មការផែនការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ស្ថិតនៅក្នុងអគ្គនាយកដ្ឋានផែនការនៃក្រសួងផែនការ ។

**ប្រការ២** : ក្រុមការងារនេះមានសមាសភាព :

| | | | | |
|---|---|---|---|---|
| ១- ឯកឧត្តម ហ៊ូ តាំងអេង | អគ្គនាយកផែនការ | ប្រធាន | ១៤- លោក សួន សុខឃឹម | សមាជិក |
| ២- លោក ហ៊ីង ច័ន្ទមុន្នា | ប្រ.នា.វិនិយោគ | អនុប្រធាន | ១៥-- លោក លុយ ចណ្ណា | សមាជិក |
| ៣- លោក ផៃ បូរ | | សមាជិក | ១៦- លោក ជួន ចាន់ធូរ៉ា | សមាជិក |
| ៤- លោក ប៉ូច សុវណ្ណឌី | | សមាជិក | ១៧- លោក ម៉ែន សំអុន | សមាជិក |
| ៥- លោកស្រី មាស សម្បត្តិ | | សមាជិកា | ១៨- លោក មាន ថាវរៈ | សមាជិក |
| ៦- លោក ទិត្យ សុវណ្ណ | | សមាជិក | ១៩- លោក នួន ទូច | សមាជិក |
| ៧- លោក ប៉ាវ ឈាងអាន | | សមាជិក | ២០- លោក កែវ អ៊ូលី | សមាជិក |
| ៨- លោក ហួយ សុទ្ធិគុណ | | សមាជិក | ២១-លោក ហ៊ន ឌិន | សមាជិក |
| ៩- លោក ស៊ិន សេដ្ឋា | | សមាជិក | ២២- លោក ហាវ ឌីណា | សមាជិក |
| ១០-លោក ខាត់ សុខា | | សមាជិក | ២៣- លោក នុត សុខសៅរឿន | សមាជិក |
| ១១- លោក ហែល តូនី | | សមាជិក | ២៤-លោក ជ័យ ណាត | សមាជិក |
| ១២- អ្នកស្រី ទី វុឌ្ឍី | | សមាជិកា | ២៥- លោក ហេង តារាវុទ្ធី | សមាជិក |
| ១៣- លោក ឈាង វ៉ាន់ថា | | សមាជិក | ២៦- លោក សុខ វាសនា | សមាជិក |

និងមន្ត្រីបច្ចេកទេសតំណាងបណ្តាក្រសួងជាសមាជិកអនុគណៈកម្មការផែនការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ។

**ប្រការ៣** : ក្រុមការងារនេះមានភារកិច្ច :

ក-ជំនួយការដល់អនុគណៈកម្មការផែនការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ក្នុងការងាររៀបចំ និងកសាងបណ្តាកំរងឯកសារមូលដ្ឋានសំរាប់ការងារគ្រប់គ្រង និងអភិវឌ្ឍន៍មូលដ្ឋានឃុំ សង្កាត់ ដោយ :

- ធ្វើការសិក្សាស្រាវជ្រាវ ចងក្រងរាល់ឯកសារចាំបាច់សំរាប់បំរើដល់ការកសាងសមត្ថភាពរបស់សមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ ក្នុងការងារផែនការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច តាមឃុំ សង្កាត់ក្នុងបរិបទវិមជ្ឈការ
- ធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងរាល់គំរូរចនាសម្ព័ន្ធ និងខ្លឹមសារនៃផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចឃុំ សង្កាត់
- ធ្វើការចងក្រងកំរងឯកសារណែនាំពីរបៀបប្រើប្រាស់រាល់ឯកសារគំរូដែលត្រូវប្រើប្រាស់ក្នុងការកសាងផែនការ និង អភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចឃុំ សង្កាត់
- ធ្វើការសិក្សាស្រាវជ្រាវ ចងក្រងរាល់ឯកសារចាំបាច់សំរាប់បំរើដល់ការប្រមូលនិងគ្រប់គ្រងទិន្នន័យមូលដ្ឋានឃុំ សង្កាត់
- ធ្វើការចងក្រងកំរងឯកសារណែនាំពីរបៀបប្រមូលនិងចងក្រងទិន្នន័យមូលដ្ឋានឃុំ សង្កាត់ ។

ខ-ជំនួយការដល់អនុគណៈកម្មការផែនការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ក្នុងការងារអភិវឌ្ឍន៍សមត្ថភាពរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការងារគ្រប់គ្រង និងអភិវឌ្ឍន៍មូលដ្ឋានឃុំ សង្កាត់ ដោយ :

- រៀបចំផែនការការងារបណ្តុះបណ្តាលមន្ត្រីក្នុងប្រព័ន្ធផែនការជាតិដែលត្រូវពាក់ព័ន្ធក្នុងក្របខ័ណ្ឌការងារផែនការ និង អភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី____ ខែ____ ឆ្នាំ____

- រៀបចំនិងបណ្តុះបណ្តាល បំពាក់សមត្ថភាពអំពីការងាររៀបចំកសាងផែនការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងការប្រមូល វិភាគ និងចងក្រងទិន្នន័យមូលដ្ឋានឃុំ សង្កាត់ ក្នុងបរិបទវិមជ្ឈការ វិសហមជ្ឈការជូនមន្ត្រីផែនការទាំងនៅថ្នាក់ជាតិ ថ្នាក់ខេត្ត ក្រុង ស្រុក ខ័ណ្ឌ និងឃុំ សង្កាត់។

**ប្រការ៤** : ក្នុងការអនុវត្តន៍ភារកិច្ចរបស់ខ្លួន ដើម្បីសំរេចបានលទ្ធផលការងារល្អនិងប្រកបដោយប្រសិទ្ធភាព ក្រុមការងារនេះអាចអញ្ជើញមន្ត្រីជំនាញតំណាងក្រសួងដែលជាសមាជិកអនុគណៈកម្មការផែនការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច មកចូលរួមប្រជុំ ពិគ្រោះយោបល់ទៅតាមករណីចាំបាច់មុននឹងស្នើសុំយោបល់ពីអនុគណៈកម្មការផែនការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ។

**ប្រការ៥** : ក្រុមការងារនេះត្រូវសហការជាមួយទីប្រឹក្សាអន្តរជាតិ គ្រប់មន្ត្រីពាក់ព័ន្ធទាំងក្នុងក្របខ័ណ្ឌរដ្ឋាភិបាល ៸ អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ ផ្នែកឯកជន ។ល។ ដើម្បីធ្វើការពិគ្រោះយោបល់ និងលើកសំណើសុំការអនុម័តពីអនុគណៈកម្មការផែនការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ដើម្បីអោយបំពេញរាល់ការងារជាភារកិច្ចរបស់ខ្លួនអោយមានប្រសិទ្ធភាព និងទាន់ពេលវេលា ។

**ប្រការ៦** : គ្រប់សមាជិក សមាជិកា ក្រុមការងារនេះត្រូវធ្វើការងារជាប្រចាំក្រោមការចាត់ចែង ដឹកនាំ និងគ្រប់គ្រងដោយប្រធានក្រុម ហើយក្នុងករណីប្រធានក្រុមអវត្តមាន នោះត្រូវស្ថិតក្រោមការដឹកនាំរបស់អនុប្រធានក្រុម ។

**ប្រការ៧** : ក្រុមការងារនេះមានការិយាល័យប្រចាំការអចិន្ត្រៃយ៍នៅជាមួយនឹងការិយាល័យ ឯកឧត្តមអគ្គនាយកផែនការ នៃក្រសួងផែនការ ។

**ប្រការ៨** : ក្រុមការងារនេះត្រូវអនុវត្តរបបរាយការណ៍ពីរសប្តាហ៍ម្តងដោយទៀងទាត់អំពីលទ្ធផលការងារនិងទិសដៅការងាររបស់ខ្លួនមកអនុគណៈកម្មការផែនការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ។

**ប្រការ៩** : ឯកឧត្តម លោកស្រី អស់លោក ដូចមានចែងក្នុងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**<u>ចម្លងជូន</u>**

- ខុទ្ទកាល័យទីស្តីការគណៈរដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ឯកឧត្តមរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការក្រ.ផែនការ
- នាយកដ្ឋានបុគ្គលិក ក្រ. ផែនការ

  " ដើម្បីជ្រាបជាពត៌មាន"
- ដូចប្រការ២ " ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

នាយ - ចន